# សង្គហគាថា

## SAṄGAHAGĀTHĀ

សម្រាប់ជំនួយដល់អដ្គធម្មកជិក

រៀបរៀងដោយ

អគ្គទត្តោ. គល់-សុភាព

ផ្សាយចេញពីវត្តតបោស្មសាន ខេត្តកំពង់ឆ្នាំង

ព.ស. ២៥៥៨ គ.ស.២០១៥

# សង្គហគាថា

**SAṄGAHAGÃTHÃ**

សម្រាប់ជំនួយដល់អង្គធម្មកឋិក

រៀបរៀងដោយ

អគទត្តោ. **គល់~សុភាព**

ផ្សាយចេញពីវត្ត តបោស្សសាន ខេត្តកំពង់ឆ្នាំង

ព.ស.២៥៥៨ គ.ស.២០១៥


អគ្គឧត្តោ.គល់_សុភាព

# សមារម្ភកថា

សៀវភៅនេះគឺជាការប្រមូលនូវគាថាផ្សេងៗ ដោយអន្លើៗ យ៉ាងសង្ខេប ដោយច្រើននោះគឺខ្ញុំដកយកពីគាថាធម្មបទ ក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ ហើយមានរាយជាមាតិកាក្នុងវគ្គទាំង ២៦ និងមាតិការឿងក្នុងវគ្គនីមួយៗផងដែរ ។ វាមិនប្លែកអ្វីពីសៀវភៅដែលអស់លោកធ្លាប់បេញផ្សាយកន្លងមកទេ ។

បំពោះពុទ្ធគាថា សុទ្ធតែល្អ និងមានអត្ថន័យជាគម្ពីរភាពទាំងអស់ ប៉ុន្តែខ្ញុំដកយកតែគាថាណាខ្លីៗ ងាយស្រួលទន្ទេញឆាប់ចាំ ។ បំពោះអង្គធម្មកថិក ដែលមាននិស្ស័យក្នុងការសម្តែងធម៌ ឬផ្សព្វផ្សាយព្រះធម៌តាមមធ្យោបាយផ្សេងៗ នាបច្ចុប្បន្ន-សម័យ គឺអាចយកកូនសៀវភៅនេះជាប់តាមខ្លួន ហើយបរិកម្មវារឿយៗបានគ្រប់ពេលនិងគ្រប់ទីកន្លែង ។ ការសម្តែងអាស្រ័យទៅលើស្ថាយឬតិចនិក ថាតើគួរលើកយករឿងនិទានណាមួយដែលខ្លួនពេញចិត្ត ឬគាថាណាដែលវាសាប់ផត ទៅនឹងសាប់រឿងឬមានអត្ថន័យទាក់ទងទៅនឹងកម្មវិធីបុណ្យរបស់ពុទ្ធបរិស័ទ ។

ដោយសម្លឹងឃើញទៅលើតម្រូវការការងារបច្ចុប្បន្ន របស់ពុទ្ធសាសនិកជាទូទៅដែលពេញចិត្តក្នុងការធ្វើបុណ្យទានផ្សេងៗ តាមវត្តអារាមឬតាមគេហដ្ឋានក្នុងនោះមិនភ្លេចឡើយពីធម្មទេសនា នេះវាជាឱកាសនៃអង្គធម្មកថិកដើម្បីឪវិឡប់នូវអេកូល្ហមីរបស់ផងខ្លួន ឲ្យស្របទៅនឹងសម្មាបរណកម្មម៉ាខេតធីងក្នុងសម័យកាលដែលតិចណូឡូជីកំពុងត្រូវបានវិវត្តទៅមុខឥតឈប់ឈរ ។

**វត្តតបោស្សសាន ថ្ងៃសៅរ៍ ព.ស.២៥៥៨ = ថ្ងៃទី ៤ -១- ២០១៥**

**អគ្គទត្តោ. គល់-សុភាព**

## ឈ្មោះអ្នកជួយពិនិត្យ

- សាមណេរ ចិត្តរក្ខិតោ. **សៅ - ចាន់ណា** (វត្តតបោស្នសាន)
- សាមណេរខេមបណ្ឌិតោ.**ប៊ុន - ចាន់សុខេន** (វត្តតបោស្នសាន)

.........................

## អ្នកចូលរួមបោះពុម្ព

សា.អគ្គទត្តោ. គល់ - សុភាព ..........................................៤០០០០៛

ឧបាសិកា យ៉ន - ណៃ (កោះជ័យទាត់) .............................៤០០០០៛

សា.ខេមបណ្ឌិតោ. ប៊ុន-ចាន់សុខេន..........................................២០០០០៛

ឧបាសក សុខ - សាក់ + ឧបាសិកា តាន់ - ហៀង ..................១០០០០៛

លោកគ្រូ លី - ប៊ុនហេង (English Teacher) ....................២ ដុល្លារ

ឧបាសក នៅភូមិសន្ទួច ........................................................៥០០០៛

# ធម្មបទដ្ឋកថាមាន២៦វគ្គ

១.យមកវគ្គ

២.អប្បមាទវគ្គ

៣.ចិត្តវគ្គ

៤.បុប្ផវគ្គ

៥.ពាលវគ្គ

៦.បណ្ឌិតវគ្គ

៧.អរហន្តវគ្គ

៨.សហស្សវគ្គ

៩.បាបវគ្គ

១០.ទណ្ឌវគ្គ

១១.ជរាវគ្គ

១២.អត្តវគ្គ

១៣.លោកវគ្គ

១៥.សុខវគ្គ

១៤.ពុទ្ធវគ្គ

១៦.បិយវគ្គ

១៧.កោធវគ្គ

១៨.មលវគ្គ

១៩.ធម្មដ្ឋវគ្គ

២០.មគ្គវគ្គ

២១.បកិណ្ណកវគ្គ

២២.និរយវគ្គ

២៣.នាគវគ្គ

២៤.តណ្ហាវគ្គ

២៥.ភិក្ខុវគ្គ

២៦.ព្រាហ្មណវគ្គ

## យមកវគ្គមាន ១៤ រឿងគឺ :

១- រឿងព្រះបក្ខុបាលត្ថេរ

២- រឿងមដ្ឋកុណ្ឌលី

៣- រឿងព្រះតិស្សៈ

៤- រឿងយក្ខិនីបងប្អូនគ្នា

៥- រឿងភិក្ខុក្រុងកោសម្ពី

៦- រឿងចុល្លកាល-មហាកាល

៧- រឿងភិក្ខុទេវទត្ត

៨- រឿងអាចារ្យសញ្ជ័យ

៩- រឿងព្រះនន្ទត្ថេរ

១០- រឿងនាយចុន្ទសូករិក

១១- រឿងធម្មិកឧបាសក

១២- រឿងភិក្ខុទេវទត្ត (ធរណីស្រូប)

១៣- រឿងនាងសុមនា

១៤- រឿងភិក្ខុជាសម្លាញ់ពីររូប

## អប្បមាទវគ្គមាន ៩ រឿងគឺ :

១- រឿងនាងសាមាវតី

២- រឿងឃោសកសេដ្ឋី

៣- រឿងព្រះចូឡបន្ថក:

៤- រឿងឥក្ខុត្តឬក្សនៃជិតពាល

៥- រឿងព្រះមហាកស្សបៈ

៦- រឿងភិក្ខុជាសម្លាញ់ពីររូប

៧- រឿងសក្កទេវរាជ

៨- រឿងភិក្ខុមួយរូប

៩- រឿងព្រះនិគមវាសីតិស្សត្ថេរ

## ចិត្តវគ្គមាន ៩ រឿងគឺ :

១- រឿងព្រះមេឃិយៈ

២- រឿងភិក្ខុមួយរូប(មាតិកមាតា)

៣- រឿងឧក្កណ្ឋិតភិក្ខុ

៤- រឿងព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរ

៥- រឿងព្រះចិត្តគហត្ថេរ

៦- រឿងភិក្ខុអ្នកប្រារព្ធវិបស្សនា

៧- រឿងព្រះបូតិគត្តតិស្សត្ថេរ

៨- រឿងនន្ទគោបាល

៩- រឿងព្រះសោរេយ្យ

## បុប្ផវគ្គមាន ១២ រឿងគឺ :

១- រឿងភិក្ខុ៥០០រូបខ្វល់ខ្វាយបឋវីកសិណ

២- រឿងព្រះថេរៈបម្រើនមរីចិកម្មដ្ឋាន

៣- រឿងព្រះបាទវិឌូឌភ:
៤- រឿងនាងបតិបូជិកា
៥- រឿងកោសិយសេដ្ឋី
៦- រឿងបាដិកាជីវក
៧- រឿងឆត្តបាណិឧបាសក
៨- រឿងនាងវិសាខា
៩- រឿងព្រះអានន្ទ
១០- រឿងប្រគេនបិណ្ឌបាតព្រះកស្សប
១១- រឿងបរិនិព្វានរបស់ព្រះគោធិក:
១២- រឿងគរហាទិន្ន

## ពាលវគ្គមាន ១៥ រឿងគឺ :

១- រឿងបុរសម្នាក់ (ទុ. ស. ន.សោ)
២- រឿងសទ្ធិវិហារិកព្រះកស្សប
៣- រឿងអានន្ទសេដ្ឋី
៤ រឿងចោរទម្លាយបង្ខិចទ្រព្យ
៥- រឿងព្រះឧទាយិ
៦- រឿងភិក្ខុអ្នកក្រុងបាវា
៧- រឿងសុប្បពុទ្ធកុដ្ឋិ
៨- រឿងបុរសអ្នកភ្ជួរស្រែ

៩- រឿងនាយសុមនមាលាការ
១០- រឿងនាងឧប្បលវណ្ណាថេរី
១១- រឿងជម្ពុកាជីវក
១២- រឿងអហិប្រេត
១៣- រឿងសេដ្ឋីកូដប្រេត
១៤- រឿងព្រះសុធម្មត្ថេរ
១៥- រឿងព្រះវនវាសីតិស្សត្ថេរ

## បណ្ឌិតវគ្គមាន ១១ រឿងគឺ :

១- រឿងព្រះរាធត្ថេរ
២- រឿងភិក្ខុអស្សជិ-បុនព្វសុកៈ
៣- រឿងព្រះឆន្នត្ថេរ
៤- រឿងព្រះមហាកប្បិន
៥- រឿងបណ្ឌិតសាមណេរ
៦- រឿងព្រះលកុណ្ឌកភទ្ទិយៈ
៧- រឿងមាតានាងកាណា
៨- រឿងភិក្ខុ៥០០រូប
៩- រឿងព្រះធម្មិកត្ថេរ
១០- រឿងការស្តាប់ធម៌
១១- រឿងអាគន្តុកភិក្ខុ

## អរហន្តវគ្គមាន ១០ រឿងគឺ :

១- រឿងពេទ្យឈ្មោះជីវក

២- រឿងព្រះមហាកស្សប

៣- រឿងព្រះវេឡដ្ឋសីសៈ

៤- រឿងព្រះមហាកច្ចាយនៈ

៥- រឿងព្រះសារីបុត្រ

៦- រឿងព្រះអនុរុទ្ធ

៧- រឿងព្រះតិស្សៈអ្នកក្រុងកោសម្ពី

៨- រឿងព្រះសារីបុត្រ

៩- រឿងព្រះខទិរវនិយរេវតៈ

១០- រឿងស្ត្រីម្នាក់

## សហស្សវគ្គមាន ១៤ រឿងគឺ :

១- រឿងចោរឈ្មោះតម្ពទាឋិកៈ

២- រឿងព្រះទារុចីរិយៈ

៣- រឿងព្រះនាងកុណ្ឌលកេសី

៤- រឿងព្រះអនត្ថបុច្ឆកព្រាហ្មណ៍

៥- រឿងឪពុកមាព្រះសារីបុត្រ

៦- រឿងក្មួយព្រះសារីបុត្រ

៧- រឿងព្រាហ្មណ៍ជាសម្លាញ់ព្រះសារីបុត្រ

៨- រឿងអាយុវឌ្ឍនកុមារ

៩- រឿងសង្កិច្ចសាមណេរ

១០- រឿងព្រះខានុកោណ្ឌញ្ញ

១១- រឿងព្រះសប្បទាសត្ថេរ

១២- រឿងនាងបដាចារ

១៣- រឿងនាងកិសាគោតមី

១៤- រឿងនាងពហុបុត្តិកាថេរី

**បាបវគ្គមាន ១២ រឿងគឺ :**

១- រឿងចូឡសាដកព្រាហ្មណ៍

២- រឿងព្រះសេយ្យកត្ថេរ

៣- រឿងនាងលាជធីតា

៤- រឿងអនាថបិណ្ឌិកសេដ្ឋី

៥- រឿងភិក្ខុមិនបេះទុកដាក់បរិក្ខារ

៦- រឿងសេដ្ឋីជើងឆ្មារ

៧- រឿងមហាធនពាណិជ

៨- រឿងព្រានកុក្កុដមិត្រ

៩- រឿងព្រានសុនខឈ្មោះកោកៈ

១០- រឿងព្រះតិស្សៈនិងជាងកែវមណី

១១- រឿងជន៣នាក់

១២- រឿងព្រះបាទសុប្បពុទ្ធសក្យ

## ទណ្ឌវគ្គមាន ១១ រឿងគឺ :

១- រឿងឆព្វគ្គិយភិក្ខុទី១

២- រឿងឆព្វគ្គិយភិក្ខុទី២

៣- រឿងក្មេងច្រើននាក់

៤- រឿងព្រះកោណ្ឌធាន

៥- រឿងឧបោសថកម្ម

៦- រឿងអជគរប្រេត

៧- រឿងព្រះមហាមោគ្គល្លាន

៨- រឿងភិក្ខុអ្នកមានភណ្ឌៈ

៩- រឿងសន្តតិមហាមាត្យ

១០- រឿងព្រះបិលោតិកៈ

១១- រឿងសុខសាមណេរ

## ជរាវគ្គមាន ៩ រឿងគឺ :

១- រឿងស្ត្រីជាសម្លាញ់នាងវិសាខា

២- រឿងនាងសិរិមា

៣- រឿងនាងឧត្តរាថេរី

៤- រឿងព្រះអធិមានិកភិក្ខុ

៥- រឿងព្រះនាងរូបនន្ទា

៦- រឿងព្រះនាងមល្លិកាទេវី

៧- រឿងព្រះលោឡុទាយិត្ថេរ

៨- រឿងបឋមពោធិកាល (អនេកជាតិសំសារំ...)

៩- រឿងបុត្រសេដ្ឋីធ្លាក់ខ្លួនក្រ (អចរិត្វា ព្រហ្មចរិយំ...)

## អត្តវគ្គមាន ១០ រឿងគឺ :

១- រឿងពោធិរាជកុមារ

២- រឿងព្រះឧបនន្ទសក្យបុត្រ

៣- រឿងព្រះបធានិកតិស្សត្ថេរ

៤- រឿងមាតាព្រះកុមារកស្សប

៥- រឿងមហាកាលឧបាសក

៦- រឿងភិក្ខុទេវទត្ត

៧- រឿងសង្ឃភេទនៃភិក្ខុទេវទត្ត

៨- រឿងព្រះកាលត្ថេរ

៩- រឿងចុល្លកាលឧបាសក

១០- រឿងព្រះអត្តទត្តត្ថេរ

## លោកវគ្គមាន ១១ រឿងគឺ :

១- រឿងភិក្ខុកំលោះ

២- រឿងព្រះបាទសុទ្ធោទនៈ

៣- រឿងភិក្ខុអ្នកបម្រើនវិបស្សនា

៤- រឿងអភយរាជកុមារ

៥- រឿងព្រះសមដ្ឋនត្ថេរ

៦- រឿងព្រះអង្គុលិមាល៍

៧- រឿងនាងធីតានៃជាងតម្បាញ

៨- រឿងភិក្ខុ៣០រូប

៩- រឿងនាងចិញ្ចាមាណវិកា

១០- រឿងអសទិសទាន

១១- រឿងនាយកាឡៈ បុត្រអនាថបិណ្ឌិកសេដ្ឋី

## ពុទ្ធវគ្គមាន ៩ រឿងគឺ ៈ

១- រឿងធីតារបស់មារ

២- រឿងយមកប្បាដិហារ្យផ្កាញ់តិត្ថិយ

៣- រឿងឯរកបត្តនាគរាជ

៤- រឿងបញ្ហាព្រះអានន្ទ (ឱវាទបាតិមោក្ខ)

៥- រឿងភិក្ខុមិនត្រេកអរ

៦- រឿងបុរោហិតឈ្មោះអគ្គិទត្ត

៧- រឿងបញ្ហាព្រះអានន្ទ

៨- រឿងភិក្ខុច្រើនរូប

៩- រឿងចេតិយព្រះពុទ្ធកស្សប

## សុខវគ្គមាន ៨ រឿងគឺ :

១- រឿងជម្លោះរបស់ពួកព្រះញាតិ

២- រឿងមារ

៣- រឿងបរាជ័យស្តេចបសេនទិកោសល

៤- រឿងអាពាហ៍ពិពាហ៍

៥- រឿងបុរសបាត់គោ

៦- រឿងការសោយអាហាររបស់ព្រះបាទបសេនទិកោសល

៧- រឿងព្រះតិស្ស:

៨- រឿងសក្កទេវរាជបម្រើព្រះសាស្តា

## បិយវគ្គមាន ៩ រឿងគឺ :

១- រឿងបព្វជិត៣រូប

២- រឿងកុដុម្ពិកមួយរូប

៣- រឿងចៅស្រីនាងវិសាខាស្លាប់

៤- រឿងស្តេចលិច្ឆវី

៥- រឿងអនិត្ថិគន្ធកុមារ

៦- រឿងព្រាហ្មណ៍ម្នាក់

៧- រឿងក្មេង៥០០នាក់

៨- រឿងព្រះអនាគាមិត្ថេរ

៩- រឿងនាយនន្ទិយ:

## កោធវគ្គមាន ៨ រឿងគឺ :

១- រឿងនាងរោហិណី
២- រឿងភិក្ខុមួយរូប
៣- រឿងឧបាសិកាឧត្តរា
៤- រឿងបញ្ហាព្រះមោគ្គល្លាន
៥- រឿងបញ្ហាភិក្ខុទូលសួរ
៦- រឿងនាងបុណ្ណាទាសី
៧- រឿងអតុលឧបាសក
៨- រឿងឆព្វគ្គិយភិក្ខុ

## មលវគ្គមាន ១២ រឿងគឺ :

១- រឿងគោឃាតកៈ
២- រឿងព្រាហ្មណ៍ម្នាក់
៣- រឿងភិក្ខុកើតជាសត្វចៃ
៤- រឿងព្រះលោឡុទាយី
៥- រឿងកុលបុត្រម្នាក់
៦- រឿងភិក្ខុចូឡសារី
៧- រឿងឧបាសក៥នាក់
៨- រឿងភិក្ខុកំលោះឈ្មោះតិស្សៈ
៩- រឿងឧបាសក៥នាក់

១០- រឿងមេណ្ឌកសេដ្ឋី

១១- រឿងព្រះឧជ្ឈានសញ្ញី

១២- រឿងសុភទ្ទបរិព្វាជក

## ធម្មដ្ឋវគ្គមាន ១០ រឿងគឺ :

១- រឿងអាមាត្យអ្នកវិនិច្ឆ័យ

២- រឿងឆព្វគ្គិយភិក្ខុ

៣- រឿងព្រះឯកុទានត្ថេរ

៤- រឿងព្រះកុណ្ឌកភទ្ទិយត្ថេរ

៥- រឿងភិក្ខុច្រើនរូប

៦- រឿងភិក្ខុឈ្មោះហត្ថកៈ

៧- រឿងព្រាហ្មណ៍ម្នាក់

៨- រឿងតិត្ថិយ

៩- រឿងអរិយៈស្ទូចត្រី

១០- រឿងភិក្ខុច្រើនរូប

## មគ្គវគ្គមាន ១០ រឿងគឺ :

១- រឿងភិក្ខុ ៥០០ រូប

២- រឿងភិក្ខុ ៥០០ រូបដទៃទៀត

៣- រឿងព្រះបធានកម្មិកតិស្សត្ថេរ

៤- រឿងសូករប្រេត

៥- រឿងភិក្ខុបោឋិលៈ

៦- រឿងព្រះថេរៈចាស់

៧- រឿងសទ្ធិវិហារិកព្រះសារីបុត្រ

៨- រឿងនាងកិសាគោតមី

៩- រឿងមហាធនពាណិជ

១០- រឿងនាងបដាចារ

**បកិណ្ណកវគ្គមាន ៩ រឿងគឺ :**

១- រឿងបុព្វកម្មរបស់ព្រះអង្គ

២- រឿងកុមារិកាស៊ីស៊ុតមាន់

៣- រឿងភិក្ខុអ្នកនគរភទ្ទិយៈ

៤- រឿងព្រះកុណ្ឌកភទ្ទិយត្ថេរ

៥- រឿងនាយទារុសាដិក

៦- រឿងភិក្ខុវជ្ជីបុត្រ

៧- រឿងចិត្តគហបតី

៨- រឿងចូឡសុភទ្រា

៩- រឿងព្រះឯកវិហារីថេរៈ

**និរយវគ្គមាន ៩ រឿងគឺ :**

១- រឿងនាងសុន្ទរី

២- រឿងសត្វត្រូវទុក្ខបៀតបៀន

៣- រឿងភិក្ខុនៅឆ្នេរស្ទឹងវគ្គមុទា

៤- រឿងសេដ្ឋីបុត្រឈ្មោះខេមកៈ

៥- រឿងភិក្ខុប្រដៅក្រ

៦- រឿងស្ត្រីត្រូវសេចក្តីប្រច័ណ្ឌគ្របសង្កត់

៧- រឿងអាគន្តុកភិក្ខុ

៨- រឿងនិគ្រន្ថ

៩- រឿងសាវកតិរ្ថិយ

## នាគវគ្គមាន ៨ រឿងគឺ :

១- រឿងរបស់ព្រះអង្គ

២- រឿងភិក្ខុធ្លាប់ជាហ្មដំរី

៣- រឿងបុត្ររបស់ព្រាហ្មណ៍ចាស់

៤- រឿងព្រះបាទបសេនទិកោសល

៥- រឿងសានុសាមណេរ

៦- រឿងដំរីឈ្មោះបាវេរកៈ

៧- រឿងភិក្ខុប្រើនរូប

៨- រឿងមារ

## តណ្ហាវគ្គមាន ១២ រឿងគឺ :

១- រឿងត្រីឈ្មោះកបិលៈ

២- រឿងកូនជ្រូកញី

៣- រឿងភិក្ខុសឹកទៅធ្វើចោរ

៤- រឿងពន្ធនាគារ

៥- រឿងព្រះនាងខេមា

៦- រឿងបុត្រសេដ្ឋីអ្នកលេងរបាំ

៧- រឿងបូឡធនុគ្គហបណ្ឌិត

៨- រឿងមារ

៩- រឿងឧបកាជីវក

១០- រឿងសក្កទេវរាជ

១១- រឿងសេដ្ឋីគ្មានកូន

១២- រឿងអង្កុរទេវបុត្រ

## ភិក្ខុវគ្គមាន ១២ រឿងគឺ :

១- រឿងភិក្ខុ៥រូប

២- រឿងភិក្ខុសម្លាប់ហង្ស

៣- រឿងកោកាលិកភិក្ខុ

៤- រឿងព្រះធម្មារាមត្ថេរ

៥- រឿងភិក្ខុគប់ភិក្ខុ

៦- រឿងបញ្ចគ្គទាយកព្រាហ្មណ៍

៧- រឿងភិក្ខុច្រើនរូប

៨- រឿងភិក្ខុ៥០០រូប

៩- រឿងព្រះសន្តកាយត្ថេរ

១០- រឿងព្រះនង្គលកូដត្ថេរ

១១- រឿងព្រះវក្កលិ

១២- រឿងសុមនសាមណេរ

## ព្រាហ្មណវគ្គមាន ៣៩ រឿងគឺ :

១- រឿងព្រាហ្មណ៍ច្រើនដោយសេចក្តីជ្រះថ្លា

២- រឿងភិក្ខុច្រើនរូប

៣- រឿងមារ

៤- រឿងព្រាហ្មណ៍ម្នាក់

៥- រឿងព្រះអានន្ទ (រុងរឿង៥យ៉ាង)

៦- រឿងបព្វជិតមួយរូប

៧- រឿងព្រះសារីបុត្រ

៨- រឿងព្រះនាងមហាបជាបតិគោតមី

៩- រឿងព្រះសារីបុត្រ

១០- រឿងព្រាហ្មណ៍ជដិល

១១- រឿងព្រាហ្មណ៍និយាយកុហក

១២- រឿងនាងកិសាគោតមី

១៣- រឿងព្រាហ្មណ៍ម្នាក់

១៤- រឿងឧគ្គសេន

១៥- រឿងព្រាហ្មណ៍ពីរនាក់
១៦- រឿងអក្កោសកភារទ្វាជព្រាហ្មណ៍
១៧- រឿងព្រះសារីបុត្រ
១៨- រឿងនាងឧប្បលវណ្ណាថេរី
១៩- រឿងព្រាហ្មណ៍មួយរូប
២០- រឿងនាងខេមាភិក្ខុនី
២១- រឿងព្រះតិស្សៈនៅញកភ្នំ
២២- រឿងភិក្ខុមួយរូប
២៣- រឿងសាមណេរ
២៤- រឿងព្រះមហាបន្ថកត្ថេរ
២៥- រឿងព្រះបិលិន្ទវច្ឆត្ថេរ
២៦- រឿងភិក្ខុមួយរូប
២៧- រឿងព្រះសារីបុត្រ
២៨- រឿងព្រះមហាមោគ្គល្លាន
២៩- រឿងព្រះរេវតៈ
៣០- រឿងព្រះចន្ទាភៈ
៣១- រឿងព្រះសីវលិ
៣២- រឿងព្រះសុន្ទរសមុទ្ទ
៣៣- រឿងព្រះជោតិកៈ

៣៤- រឿងភិក្ខុធ្លាប់ជាអ្នករបាំទី១

៣៥- រឿងភិក្ខុធ្លាប់ជាអ្នករបាំទី២

៣៦- រឿងព្រះវង្គីសៈ

៣៧- រឿងព្រះនាងធម្មទិន្នាថេរី

៣៨- រឿងព្រះអង្គុលិមាល៍

៣៩- រឿងទេវហិតព្រាហ្មណ៍

# យមកវគ្គទី១

**មនោបុព្វង្គមា ធម្មា  មនោសេដ្ឋា មនោមយា**
**មនសា ចេ បទុដ្ឋេន  ភាសតិ វា ករោតិ វា**
**តតោ នំ ទុក្ខមន្វេតិ  ចក្កំវ វហតោ បទំ ៗ**

*ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត(មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គល មានចិត្តត្រូវទោសប្រទូស្តហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមដានជើងគោដែលកំពុងអូសទៅ ។*

**មនោបុព្វង្គមា ធម្មា  មនោសេដ្ឋា មនោមយា**
**មនសា ចេ បសន្នេន  ភាសតិ វា ករោតិ វា**
**តតោ នំ សុខមន្វេតិ  ឆាយាវ អនុបាយិនី ៗ**

*ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី (នូវសុចរិត)ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ ។*

**ន ហិ វេរេន វេរានិ  សម្មន្តីធ កុទាចនំ**
**អវេរេន ច សម្មន្តិ  ឯស ធម្មោ សនន្តនោ ៗ**

តាមពិត តាំងពីកាលណាមកក្នុងលោកនេះ ពៀរទាំងឡាយមិនរម្ងាប់ដោយពៀរឡើយ ពៀរទាំងឡាយ តែងរម្ងាប់ដោយមិនមានពៀរ នេះជាបវេណីធម៌ ។

**សុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ**
**ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ**
**តំ វេ បសហតី មារោ វាតោ រុក្ខំវ ទុព្វលំ ។**

បុគ្គលដែលយល់នូវអារម្មណ៍ថាល្អ មិនសង្រួមក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមធូរថយ, កិលេសមាររមែងគ្របសង្កត់បុគ្គលនោះឯង ដូចខ្យល់ដែលគ្របសង្កត់ដើមឈើទុព្វលដូច្នោះ ។

**អសុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ**
**ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវីរិយំ**
**តំ វេ នប្បសហតី មារោ វាតោ សេលំវ បព្វតំ ។**

ឯបុគ្គល ដែលយល់ឃើញនូវអារម្មណ៍ ថាមិនល្អ សង្រួមប្រពៃក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន មានសទ្ធា ប្រារព្ធព្យាយាម កិលេសមារមិនអាចគ្របសង្កត់បុគ្គលនោះបាន ដូចខ្យល់គ្របសង្កត់ភ្នំថ្មតាន់មិនបានដូច្នោះ ។

**យថា អគារំ ទុច្ឆន្នំ វុដ្ឋី សមតិវិជ្ឈតិ**
**ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។**

ផ្ទះដែលប្រក់ខ្ជីខ្ជាហើយ តំណក់ទឹកភ្លៀង រមែងលេចស្រោចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំហើយ រាគៈរមែងចាក់ដោត យ៉ាងនោះឯង ។

**យថា អគារំ សុឆន្នំ វុដ្ឋី ន សមតិវិជ្ឈតិ**
**ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ៕**

ផ្ទះដែលប្រក់ល្អហើយ តំណក់ទឹកភ្លៀង រមែងមិនលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលបានអប់រំទុកល្អហើយ រាគៈរមែងមិនចាក់ដោតបាន យ៉ាងនោះឯង ។

**ឥធ សោចតិ បេច្ច សោចតិ បាបការី ឧភយត្ថ សោចតិ**
**សោ សោចតិ សោ វិហញ្ញតិ ទិស្វា កម្មកិលិដ្ឋមត្តនោ ៕**

បុគ្គលអ្នកធ្វើបាប តែងសោកស្តាយក្នុងលោកទាំងពីរ គឺសោក-ស្តាយក្នុងលោកនេះផង សោកស្តាយក្នុងលោកខាងមុខផង បុគ្គលនោះរមែងសោកស្តាយ ក្តៅក្រហាយ ព្រោះឃើញអំពើសៅហ្មងរបស់ខ្លួន ។

**ឥធ តប្បតិ បេច្ច តប្បតិ បាបការី ឧភយត្ថ តប្បតិ**
**បាបំ មេ កតន្តិ តប្បតិ ភិយ្យោ តប្បតិ ទុគ្គតឹ គតោ**

បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺក្តៅក្រហាយក្នុងលោកនេះផង ក្តៅក្រហាយក្នុងលោកខាងមុខផង បុគ្គលនោះរមែងក្តៅក្រហាយដោយគិតឃើញថា បាបអញបានធ្វើហើយ, លុះស្លាប់ទៅកាន់ទុគ្គតិ ក៏រឹងរឹតតែក្តៅក្រហាយដ៏ក្រៃលែង ។

**ឥធ មោទតិ បេច្ច មោទតិ  កតបុញ្ញោ ឧភយត្ថ មោទតិ**
**សោ មោទតិ សោ បមោទតិ  ទិស្វា កម្មវិសុទ្ធិមត្តនោ ។**

*បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះផង រីករាយក្នុងលោកខាងមុខផង បុគ្គលនោះរមែងរីករាយស្រស់ស្រាយ ព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន ។*

**ឥធ នន្ទតិ បេច្ច នន្ទតិ  កតបុញ្ញោ ឧភយត្ថ នន្ទតិ**
**បុញ្ញំ មេ កតន្តិ ភិយ្យោ  នន្ទតិ សុគតឹ គតោ ។**

*បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរក្នុងលោកទាំងពីរ គឺត្រេកអរក្នុងលោកនេះផង ត្រេកអរក្នុងលោកខាងមុខផង បុគ្គលនោះរមែងត្រេកអរដោយគិតឃើញថា បុណ្យអញបានធ្វើហើយ, លុះមរណកាលទៅកាន់សុគតិ ក៏រឹងរឹតតែត្រេកអរដ៏ក្រៃលែង ។*

# អប្បមាទវគ្គទី២

**អប្បមាទោ អមតំបទំ  បមាទោ មច្ចុនោ បទំ**
**អប្បមត្តា ន មីយន្តិ  យេ បមត្តា យថា មតា**
**ឯតំ វិសេសតោ ញត្វា  អប្បមាទម្ហិ បណ្ឌិតា ។**

*សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយណាដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់ ជនទាំងឡាយណាដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅ*

ហើយ, ពួកបណ្ឌិតបានជ្រាបនូវដំណើរនេះដោយប្លែកៗគ្នា(ទើបឋិតនៅ) ក្នុងសេចក្តីមិនប្រមាទ ។

**បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា**
**អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ៕**

ពួកជនពាលអប្បឥតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុកនូវសេចក្តីមិនប្រមាទ ដូច(រក្សា)ទ្រព្យយ៉ាងប្រសើរ ។

**មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ**
**អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ ៕**

អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗនូវសេចក្តីប្រមាទ ចូរកុំប្រកបរឿយៗនូវសេចក្តីរីករាយត្រេកអរក្នុងកាមឡើយ ដ្បិតបុគ្គលអ្នកមិនប្រមាទ ខំសង្កេតពិនិត្យ រមែងបានសេចក្តីសុខដ៏ទូលាយ ។

**អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ**
**អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ ៕**

បណ្ឌិតមានប្រាជ្ញាមោះមុត កាលពួកបុគ្គលកំពុងប្រមាទ លោកមិនប្រមាទ កាលពួកបុគ្គលកំពុងដេកលក់ លោកភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែបនោះ ដូចជាសេះលឿនដែលទៅចោលនូវសេះមានកម្លាំងខ្សោយដូច្នោះ ។

**អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ**
**អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា ។**

*មឃមាណព ដល់នូវភាពជាបុគ្គលប្រសើរបំផុត ជាងទេវតាទាំងឡាយ ព្រោះតែសេចក្តីមិនប្រមាទ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវសេចក្តីមិនប្រមាទ (ហើយ)តិះដៀលនូវសេចក្តីប្រមាទសព្វៗកាល ។*

# ចិត្តវគ្គទី៣

**ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ**
**យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។**

*អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហាគឺមហាភូតរូប៤ ជាទីអាស្រ័យនៅ, អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ ។*

**កុម្ភូបមំ កាយមិមំ វិទិត្វា**
**នគរូបមំ ចិត្តមិទំ ថបេត្វា**
**យោធេថ មារំ បញ្ញាវុធេន**
**ជិតញ្ច រក្ខេ អនិវេសនោ សិយា ។**

*បុគ្គលគប្បីដឹងច្បាស់នូវកាយនេះ ថាដូចជាឆ្នាំង គប្បីបិទនូវចិត្តនេះឲ្យដូចជាបិទទ្វារនគរ គប្បីច្បាំងនូវមារដោយអាវុធគឺបញ្ញា គប្បីរក្សាទុកនូវធម៌ដែលខ្លួនឈ្នះហើយ មិនគប្បីជាអ្នកជំអក់នៅ(ក្នុងធម៌នោះ)ឡើយ ។*

## បុប្ផវគ្គទី៤

**បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ**

**សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។**

*មច្ចុគឺសេចក្ដីស្លាប់ តែងកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ចំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ៥ នុ៎ះឯងដូចទឹកជំនន់ធំ ដែលកួចយកអ្នកស្រុកកំពុងដេកលក់ទៅ ដូច្នោះឯង ។*

**បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ**

**អតិត្តំយេវ កាមេសុ អន្តកោ កុរុតេ វសំ ។**

*អ្នកធ្វើនូវទីបំផុតគឺមរណៈ តែងក្រុងសត្វ ដែលមានចិត្តជាប់ចំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កាគឺកាមគុណ៥, មិនឆ្អែតឆ្អន់ក្នុងកាមទាំងឡាយ នុ៎ះឯង ឲ្យនៅក្នុងអំណាចរបស់ខ្លួន។*

**យថាបិ បុប្ផរាសិម្ហា កយិរា មាលាគុណេ ពហូ**

**ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ ។**

មាលាការ ចេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កា(ផ្សេងៗគ្នា)ឲ្យច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើនយ៉ាងនោះ ។

**ន បុប្ផគន្ធោ បដិវាតមេតិ**
**ន ចន្ទនំ តគរមល្លិកា វា**
**សតញ្ច គន្ធោ បដិវាតមេតិ**
**សព្វា ទិសា សប្បុរិសោ បវាយតិ ។**

ក្លិនផ្កាឈើ ផ្សាយទៅច្រាសខ្យល់មិនបាន ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនខ្លឹមក្រស្នាក្តី ក្លិនផ្កាម្លិះរួតក្តី ក៏ផ្សាយទៅច្រាសខ្យល់មិនបាន ចំណែកក្លិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ព្រោះសប្បុរសរមែងផ្សាយទៅបានគ្រប់ទិស ។

**អប្បមត្តោ អយំ គន្ធោ យ្វាយំ តគរចន្ទនី**
**យោ ច សីលវតំ គន្ធោ វាតិ ទេវេសុ ឧត្តមោ ។**

ក្លិនក្រស្នា និងក្លិនចន្ទន៍ណា ក្លិននេះក្រអូបមានប្រមាណតិចទេ ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយណា ក្លិននោះទើបក្រអូបលើសលប់ផ្សាយទៅក្នុងទេវលោកនិងមនុស្សលោកបាន ។

**តេសំ សម្បន្នសីលានំ អប្បមាទវិហារិនំ**
**សម្មទញ្ញា វិមុត្តានំ មារោ មគ្គំ ន វិន្ទតិ ។**

មារាធិរាជ (ទុកជាខំស្វែងរក) ក៏មិនជួបនូវផ្លូវរបស់លោកអ្នកមាន សីលបរិបូណ៌ អ្នកនៅដោយសេចក្តីមិនប្រមាទ អ្នករួចស្រឡះ(ចាកធម៌ជាគ្រឿងសៅហ្មង) ព្រោះដឹងច្បាស់តាមហេតុ ។

# ពាលវគ្គទី៥

**ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ**
**ទីឃោ ពាលានំ សំសារោ សទ្ធម្មំ អវិជានតំ ។**

រាត្រីវែង ចំពោះតែអ្នកភ្ញាក់រឭក(ដេកមិនលក់) យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្តវែងឆ្ងាយ ចំពោះតែបុគ្គលពាលមិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

**ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ**
**ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា ។**

បុគ្គលកាលស្វះស្វែងរកកល្យាណមិត្រ បើមិនបានមិត្រដែលប្រសើរជាងខ្លួន ឬមិត្រដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯងឲ្យខ្ជាប់ខ្ជួនវិញ ព្រោះថា សហាយតាគុណ[១]មិនមានក្នុងបុគ្គលពាលឡើយ ។

**បុត្តាមត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ**
**អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។**

---

១- សីល កថាវត្ថុ១០ ធុតង្គគុណ១៣ វិបស្សនាគុណ មគ្គ៤ ផល៤ វិជ្ជា៣ អភិញ្ញា៦ ។

*ជនពាលតែងព្រួយលំបាក ដោយសេចក្ដីសម្គាល់ថា កូនទាំង-ទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមានផង ចំណង់បើកូនទាំងឡាយ នឹងមានមកអំពីណា ទ្រព្យនឹងមានមកអំពីណាបាន ។*

**យោ ពាលោ មញ្ញតី ពាល្យំ បណ្ឌិតោ វាបិ តេន សោ**
**ពាលោ ច បណ្ឌិតមានី ស វេ ពាលោតិ វុច្ចតិ ។**

*អ្នកណាជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនថាជាពាល អ្នកនោះ នឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួនថាជាពាលនោះម្យ៉ាងទៀត អ្នកណាជាមនុស្សពាល តែមានសេចក្ដីប្រកាន់ថាខ្លួនជាបណ្ឌិត អ្នកនោះឈ្មោះថា ជាមនុស្សពាលដោយពិត ។*

**យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ**
**ន សោ ធម្មំ វិជានាតិ ទព្វី សូបរសំ យថា ។**

*មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិតក៏ឥតមានដឹងរសធម៌អ្វីឲ្យច្បាស់លាស់ឡើយ ដូចវែកដែលមិនដឹងនូវរសសម្ល ។*

**មុហុត្តមបិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ**
**ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា ។**

*វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែងយល់រសធម៌ដោយឆាប់រហ័ស ដូចអណ្ដាតដឹងនូវរសសម្ល ។*

**ន តំ កម្មំ កតំ សាធុ  យំ កត្វា អនុតប្បតិ**
**យស្ស អស្សុមុខោ រោទំ  វិបាកំ បដិសេវតិ ។**

*បុគ្គលធ្វើកម្មណាហើយ រមែងក្ដៅក្រហាយ ឬមានមុខប្រឡាក់ដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ ឈ្មោះថាជាកម្មមិនល្អឡើយ ។*

**តញ្ច កម្មំ កតំ សាធុ  យំ កត្វា នានុតប្បតិ**
**យស្ស បតីតោ សុមនោ  វិបាកំ បដិសេវតិ ។**

*បុគ្គលធ្វើកម្មណាហើយ រមែងមិនក្ដៅក្រហាយ ឬដល់នូវសេចក្ដីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថាជាកម្មល្អ ។*

**មធុវា មញ្ញតី ពាលោ  យាវ បាបំ ន បច្ចតិ**
**យទា ច បច្ចតី បាបំ  អថ ទុក្ខំ និគច្ឆតិ ។**

*បាបមិនទាន់ឲ្យផលត្រឹមណា ជនពាលតែងសម្គាល់នូវបាបនោះថា(ផ្អែម)ដូចទឹកឃ្មុំ លុះតែកាលណាបាបឲ្យផល ជនពាលទើបប្រទះនូវសេចក្ដីទុក្ខ ក្នុងកាលណោះ ។*

# បណ្ឌិតវគ្គទី៦

**និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ**

**និគ្គយ្ហវាទឹ មេធាវី តាទិសំ បណ្ឌិតំ ភជេ**

**តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ ។**

*បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោស ថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យ ដូច្នោះគួរគប់រកអ្នកប្រាជ្ញបែបនោះ (ព្រោះថា) កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្តីគាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ ។*

**ធម្មប្បីតិ សុខំ សេតិ វិប្បសន្នេន ចេតសា**

**អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ ។**

*បណ្ឌិត ដែលមានសេចក្តីឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរក្នុងធម៌ ដែលព្រះអរិយៈប្រកាសទុកហើយគ្រប់ពេល ។*

**ឧទកញ្ហិ នយន្តិ នេត្តិកា**

**ឧសុការោ នមយន្តិ តេជនំ**

**ទារុំ នមយន្តិ តច្ឆកា**

**អត្តានំ ទមយន្តិ បណ្ឌិតា ។**

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឲ្យត្រង់) អ្នកចាំងឈើ តែងចាំងឈើ ឯបណ្ឌិតទាំងឡាយ តែងទូន្មានខ្លួន (ដូច្នោះដែរ) ។

**សេលោ យថា ឯកឃនោ        វាតេន ន សមីរតិ**

**ឯវំ  និន្ទាបសំសាសុ            ន សមិញ្ជន្តិ បណ្ឌិតា ។**

ភ្នំថ្មតាន់ មិនកម្រើកញាប់ញ័រ ដោយខ្យល់ ដូចម្ដេចមិញ បណ្ឌិតទាំងឡាយ ក៏មិនញាប់ញ័រ ព្រោះពាក្យតិះដៀល និងពាក្យសរសើរ(ជា-ដើម)ដូច្នោះឯង ។

**ន អត្តហេតុ ន បរស្ស ហេតុ**

**ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ**

**ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ**

**ស សីលវា បញ្ញវា ធម្មិកោ សិយា ។**

បណ្ឌិតមិនគួរធ្វើអាក្រក់ ព្រោះហេតុនៃខ្លួន មិនគួរធ្វើអាក្រក់ ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាកូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរប្រាថ្នាសិទ្ធិដើម្បីខ្លួន ដោយហេតុមិនមែនជាធម៌ឡើយ លោកគួរជាអ្នកមានសីល មានប្រាជ្ញាប្រកបដោយធម៌ ។

**អប្បកា តេ មនុស្សេសុ         យេ ជនា បារគាមិនោ**

**អថាយំ ឥតរា បជា            តីរមេវានុធាវតិ ។**

*បណ្តាមនុស្សទាំងឡាយ ពួកជនណា ដែលឆ្លងដល់ត្រើយ គឺព្រះនិព្វាន ពួកជននោះ មានប្រមាណតិច ចំណែកពួកសត្វក្រៅនេះ រមែងស្ទុះទៅកាន់ត្រើយ (គឺសក្កាយទិដ្ឋិ) ។*

**យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ**

**តេ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ฯ**

*ជនទាំងឡាយណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ដែលព្រះតថាគតទ្រង់សម្តែងទុកហើយដោយប្រពៃ ជនទាំងនោះ នឹងឆ្លងនូវលំនៅនៃមច្ចុដែលមិនងាយឆ្លងបាន ហើយដល់នូវព្រះនិព្វាន ។*

**យេសំ សម្ពោធិយង្គេសុ សម្មាចិត្តំ សុភាវិតំ**

**អាទានប្បដិនិស្សគ្គេ អនុបាទាយ យេ រតា**

**ខីណាសវា ជុតិមន្តោ តេ លោកេ បរិនិព្វុតា ฯ**

*ចិត្តដែលបណ្ឌិតទាំងឡាយណា បានអប់រំល្អហើយក្នុងអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងទាំងឡាយ ឬបណ្ឌិតទាំងឡាយណាមិនប្រកាន់មាំ ត្រេកអរតែក្នុងការលះនូវសេចក្តីប្រកាន់មាំ បណ្ឌិតទាំងឡាយនោះៗ រមែងជាអ្នកអស់អាសវៈ មានសេចក្តីរុងរឿង បរិនិព្វានក្នុងលោក ។*

## អរហន្តវគ្គទី៧

**គាមេ វា យទិ វា រញ្ញេ និន្នេ វា យទិ វា ថលេ**

**យត្ថ អរហន្តោ វិហរន្តិ តំ ភូមិរាមណេយ្យកំ ฯ**

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី ទីទាបក្តី ទីទួលក្តី ទីនោះឯង ជាភូមិគួរត្រេកអរ ។

**រមណិយានិ អរញ្ញានិ   យត្ថ ន រមតី ជនោ**

**វីតរាគោ រមេស្សន្តិ   ន តេ កាមគវេសិនោ ៕**

ជន (អ្នកស្វែងរកកាម) រមែងមិនត្រេកអរ ក្នុងព្រៃដែលគួររីករាយទេ ព្រះខីណាស្រពដែលមានរាគៈទៅប្រាសហើយ ទើបត្រេកអរ ក្នុងព្រៃនោះ ព្រោះលោកជាអ្នកមិនស្វែងរកកាម ។

# សហស្សវគ្គទី៨

**សហស្សមបិ ចេ វាចា   អនត្ថបទសញ្ហិតា**

**ឯកំ អត្ថបទំ សេយ្យោ   យំ សុត្វា ឧបសម្មតិ ៕**

បើវាចា សូម្បី១ពាន់ម៉ាត់ ជាវាចាប្រកបដោយបទឥតប្រយោជន៍ វាចានោះ ពុំប្រសើរឡើយ អ្នកណាស្តាប់បទមានប្រយោជន៍ណាហើយ រមែងស្ងប់រម្ងាប់បាន បទមានប្រយោជន៍នោះ សូម្បី១បទ ក៏ឈ្មោះថាប្រសើរជាង ។

**សហស្សមបិ ចេ គាថា   អនត្ថបទសញ្ហិតា**

**ឯកំ គាថាបទំ សេយ្យោ   យំ សុត្វា ឧបសម្មតិ ៕**

*បើគាថា សូម្បី១ពាន់ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថានោះពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថានោះ សូម្បី១បទ ក៏ឈ្មោះថាប្រសើរជាង ។*

**យោ ច គាថា សតំ ភាសេ អនត្ថបទសញ្ហិតា**

**ឯកំ ធម្មបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។**

*អ្នកណា គប្បីពោលគាថាមួយរយ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថាដែលអ្នកនោះពោលហើយនោះ ពុំប្រសើរឡើយ អ្នក-ណាស្តាប់បទនៃធម៌ហើយ រមែងស្ងប់រម្ងាប់បាន បទនៃធម៌នោះ សូម្បីតែមួយបទ ក៏ឈ្មោះថាប្រសើរជាង ។*

**យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ**

**ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ ។**

*អ្នកណា គប្បីឈ្នះពួកមនុស្ស ក្នុងសង្គ្រាមអស់មួយពាន់ៗដង គឺមួយលាននាក់ ចំណែកអ្នកណា ឈ្នះខ្លួនឯងតែម្នាក់បាន អ្នកនោះឈ្មោះថាជាមនុស្សខ្ពង់ខ្ពស់ ជាងអ្នកដែលឈ្នះក្នុងសង្គ្រាមនោះ ។*

**អត្តា ហវេ ជិតំ សេយ្យោ យា ចាយំ ឥតរា បជា**

**អត្តទន្តស្ស បោសស្ស និច្ចំ សញ្ញតចារិនោ**

**នេវ ទេវោ ន គន្ធព្វោ ន មារោ សហ ព្រហ្មុនា**

**ជិនំ អបជិតំ កយិរា តថារូបស្ស ជន្តុនោ ។**

*ឈ្នះខ្លួនឯងប្រសើរជាង ចំណែកពួកសត្វក្រៅនេះដែលគេឈ្នះហើយ មិនប្រសើរឡើយ កាលបើបុគ្គលមានខ្លួនទូន្មានហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច, ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើនូវជម្នះរបស់សត្វមានសភាពដូច្នោះ ឲ្យត្រលប់ចាញ់វិញបានឡើយ ។*

**មាសេ មាសេ សហស្សេន យោ យជេថ សតំ សមំ**
**ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ**
**សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។**

*អ្នកណា បូជា(លោកិយមហាជន) ដោយទ្រព្យមួយពាន់ រាល់ៗខែ អស់១រយឆ្នាំ ការបូជានោះ ពុំប្រសើរស្មើនឹងអ្នកដែលបូជាចំពោះបុគ្គលមានខ្លួនអប់រំហើយ តែ ១ នាក់ សូម្បីមួយរំពេច, ការបូជាអស់១០០ឆ្នាំមិនប្រសើរឡើយ ។*

**យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។**

*បុគ្គលណា ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់ (ទោះបី) រស់នៅអស់រយនៃឆ្នាំ ពុំប្រសើរឡើយ (ចំណែក)ការរស់នៅសូម្បីត្រឹមតែមួយថ្ងៃ របស់លោកអ្នកមានសីល មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។*

**យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។**

*បុគ្គលណា អប្បឥតប្រាជ្ញា មានចិត្តមិនបានតម្កល់ខ្ជាប់ (ទោះបី)រស់នៅអស់រយនៃឆ្នាំ ពុំប្រសើរឡើយ (ចំណែក)ការរស់នៅសូម្បីត្រឹមតែមួយថ្ងៃ របស់លោកដែលមានប្រាជ្ញា មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។*

**យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ**
**ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ ឲ**

*បុគ្គលណា ជាមនុស្សខ្ជិលច្រអូស មានព្យាយាមថោកថយ (ទោះបី)រស់នៅអស់រយនៃឆ្នាំ ពុំប្រសើរឡើយ (ចំណែក)ការរស់នៅសូម្បីត្រឹមតែមួយថ្ងៃ របស់លោកដែលប្រារព្ធព្យាយាមមាំមួន ប្រសើរជាង ។*

**យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្វយំ**
**ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្វយំ ឲ**

*បុគ្គលណា មិនឃើញការកើតនិងការវិនាសទៅ (នៃសង្ខារធម៌ (ទោះបី) រស់នៅអស់រយនៃឆ្នាំ ពុំប្រសើរឡើយ (ចំណែក)ការរស់នៅសូម្បីត្រឹមតែមួយថ្ងៃ របស់លោកដែលឃើញការកើតឡើងនិងការវិនាសទៅ ប្រសើរជាង ។*

**យោ ច វស្សសតំ ជីវេ អបស្សំ អមតំ បទំ**
**ឯកាហំ ជីវិតំ សេយ្យោ បស្សតោ អមតំ បទំ ឲ**

បុគ្គលណា មិនឃើញផ្លូវនៃព្រះនិព្វាន (ទោះបី)រស់នៅអស់រយនៃឆ្នាំ ពុំប្រសើរឡើយ (ចំណែក)ការរស់នៅសូម្បីត្រឹមតែមួយថ្ងៃ របស់លោកអ្នកឃើញផ្លូវព្រះនិព្វាន ប្រសើរជាង ។

**យោ ច វស្សសតំ ជីវេ　　អបស្សំ ធម្មមុត្តមំ**

**ឯកាហំ ជីវិតំ សេយ្យោ　　បស្សតោ ធម្មមុត្តមំ ។**

បុគ្គលណា មិនឃើញធម៌ដ៏ខ្ពង់ខ្ពស់ (ទោះបី)រស់នៅអស់រយនៃឆ្នាំ ពុំប្រសើរឡើយ (ចំណែក)ការរស់នៅសូម្បីត្រឹមតែមួយថ្ងៃ របស់លោកអ្នកឃើញធម៌ដ៏ខ្ពង់ខ្ពស់ ប្រសើរជាង ។

## បាបវគ្គទី៩

**អភិត្ថរេថ កល្យាណេ　　បាបា ចិត្តំ និវារយេ**

**ទន្ធំ ហិ ករតោ បុញ្ញំ　　បាបស្មឹ រមតី មនោ ។**

បុគ្គលគួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលយឺតយូរក្នុងការធ្វើបុណ្យ ចិត្តរមែងត្រេកអរក្នុងបាប ។

**បុញ្ញញ្ចេ បុរិសោ កយិរា　កយិរាថេនំ បុនប្បុនំ**

**តម្ហិ ឆន្ទំ កយិរាថ　　សុខោ បុញ្ញស្ស ឧច្ចយោ ។**

បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឲ្យរឿយៗ គួរធ្វើសេចក្តីពេញចិត្តក្នុងបុណ្យនោះ (ព្រោះថា) ការសន្សំបុណ្យ តែងនាំមកនូវសេចក្តីសុខ ។

**មាវមញ្ញេថ បាបស្ស ន មត្តំ អាគមិស្សតិ**

**ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ**

**អាបូរតិ ពាលោ បាបស្ស ថោកំ ថោកំបិ អាចិនំ ។**

*បុគ្គល មិនគួរមើលងាយបាបថា មានប្រមាណតិច នឹងមិនឲ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយតំណក់ទឹក ដែលធ្លាក់ចុះ យ៉ាងណា បុគ្គលពាលកាលសន្សំបាប សូម្បីបន្តិចម្តងៗគង់ពេញបានដោយបាប យ៉ាងនោះដែរ ។*

**មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ**

**ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ**

**អាបូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ ។**

*បុគ្គល មិនគួរមើលងាយបុណ្យថា មានប្រមាណតិច នឹងមិនឲ្យផលដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយតំណក់ទឹក ដែលធ្លាក់ចុះ យ៉ាងណា អ្នកប្រាជ្ញកាលសន្សំបុណ្យ បន្តិចម្តងៗគង់ពេញបានដោយបុណ្យ យ៉ាងនោះ ។*

**បាណិម្ហិ ចេ វណោ នាស្ស ហរេយ្យ បាណិនា វិសំ**

**នាព្វណំ វិសមន្វេតិ នត្ថិ បាបំ អកុព្វតោ ។**

*បើដំបៅមិនមានក្នុងបាតដៃទេ បុគ្គលគប្បីនាំយកថ្នាំពិសដោយបាតដៃ ថ្នាំពិស រមែងមិនជ្រាបចូលទៅកាន់បាតដៃដែលគ្មានដំបៅ យ៉ាងណា បាបរមែងមិនមានដល់បុគ្គលអ្នកមិនធ្វើ យ៉ាងនោះដែរ ។*

**យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ**

**សុទ្ធស្ស បោសស្ស អនង្គណស្ស**

**តមេវ ពាលំ បច្ចេតិ បាបំ**

**សុខុមោ រជោ បដិវាតំវ ខិត្តោ ។**

បុគ្គលណា ប្រទូស្តចំពោះអ្នកមិនប្រទូស្តតប ជាសត្វស្អាត មិនមាន កិលេសដូចជាទីទួល បាបរមែងត្រលប់មករកបុគ្គលពាលនោះវិញ ដូច បាចធូលីល្អិត ទៅកាន់ទីច្រាសខ្យល់ ។

**ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ**

**ន បព្វតានំ វិវរំ បវិស្ស**

**ន វិជ្ជតី សោ ជគតិប្បទេសោ**

**យត្ថដ្ឋិតោ មុច្ចេយ្យ បាបកម្មា ។**

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅឰដ៏អាកាស ក្នុង កណ្តាលសមុទ្រ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះ ប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយ គប្បីរួចចាកបាបកម្មបាន នោះមិនដែលមានឡើយ ។

**ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ**

**ន បព្វតានំ វិវរំ បវិស្ស**

**ន វិជ្ជតី សោ ជគតិប្បទេសោ**

**យត្ថដ្ឋិតំ នប្បសហេយ្យ មច្ចុ ។**

បុគ្គលទៅឰដ៏អាកាស ក្នុងកណ្ដាលសមុទ្រ កាន់ចន្លោះនៃភ្នំទាំងឡាយ ក៏មិនរួចចាកសេចក្ដីស្លាប់បាន ព្រោះប្រទេសលើផែនដីដែលបុគ្គលឋិតនៅហើយ សេចក្ដីស្លាប់គ្របសង្កត់មិនបាននោះ មិនដែលមានឡើយ ។

# ទណ្ឌវគ្គទី១០

**សព្វេ តសន្តិ ទណ្ឌស្ស សព្វេ ភាយន្តិ មច្ចុនោ**

**អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។**

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំងឡាយតែងខ្លាចចំពោះសេចក្ដីស្លាប់គ្រប់ៗរូប បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមា ហើយមិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារ(សត្វដទៃ)ឡើយ ។

**សព្វេ តសន្តិ ទណ្ឌស្ស សព្វេសំ ជីវិតំ បិយំ**

**អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។**

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា (ព្រោះថា)ជីវិតជាទីស្រលាញ់របស់សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមា ហើយមិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។

**សុខកាមានិ ភូតានិ យោ ទណ្ឌេន វិហឹសតិ**

**អត្តនោ សុខមេសានោ បេច្ច សោ ន លភតេ សុខំ ។**

ជនណា ស្វែងរកសេចក្ដីសុខដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយដែលប្រាថ្នាសេចក្ដីសុខ ដោយអាជ្ញា ជននោះលះលោកនេះទៅហើយ នឹងមិនបានសេចក្ដីសុខឡើយ ។

**យថា ទណ្ឌេន គោបាលោ គាវោ បាចេតិ គោចរំ**
**ឯវំ ជរា ច មច្ចូ ច អាយុំ បាចេន្តិ បាណិនំ ។**

គង្វាលគោ រមែងកៀងគោទៅកាន់ទីគោចរដោយអាជ្ញា (គឺដំបងឬរំពាត់) ដូចម្ដេចមិញ ជរានិងមច្ចុ តែងកៀងនូវអាយុរបស់សត្វទាំងឡាយដូច្នោះឯង ។

**ឧទកំ ហិ នយន្តិ នេត្តិកា ឧសុការា នមយន្តិ តេជនំ**
**ទារុំ នមយន្តិ តច្ឆកា អត្តានំ ទមយន្តិ សុព្វតា ។**

ធម្មតាអ្នកបង្ហូរ តែងបង្ហូរទឹក អ្នកធ្វើព្រួញ តែងពត់ព្រួញ(ឲ្យត្រង់) អ្នកចាំង តែងចាំងឈើ អ្នកមានវត្តល្អ តែងទូន្មានខ្លួន ។

## ជរាវគ្គទី១១

**កោ នុ ហាសោ កិមានន្ទោ និច្ចំ បជ្ជលិតេ សតិ**
**អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ ។**

កាលបើលោកសន្និវាស ត្រូវភ្លើងមានរាគៈជាដើម ឆេះទ្រលោមជានិច្ច ម្ដេចក៏សើច ម្ដេចក៏ត្រេកត្រអាល អ្នកទាំងឡាយត្រូវងងឹតគឺអវិជ្ជារួបរឹតហើយ (ម្ដេចឡើយ) ក៏មិនស្វែងរកប្រទីបគឺប្រាជ្ញា ។

**បរិជិណ្ណមិទំ រូបំ      រោគនិឌ្ឌំ បភង្គុណំ**

**ភិជ្ជតិ បូតិ សន្ទេហោ  មរណន្តំ ហិ ជីវិតំ ។**

*រូបនេះគ្រាំគ្រាអស់ហើយ ជាទីសម្នាក់នៃរោគ ជារបស់ពុកផុយ រាងកាយជារបស់ស្អុយ(នេះ) តែងបែកធ្លាយទៅវិញ ព្រោះថាជីវិតមាន សេចក្តីស្លាប់ជាទីបំផុត ។*

**សតញ្ច ធម្មោ ន ជរំ ឧបេតិ ។**

*ធមិរបស់សប្បុរស មិនចូលដល់ការចាស់ជរាឡើយ ។ (៥៣)*

**អនេកជាតិសំសារំ      សន្ធាវិស្សំ អនិព្វិសំ**

**គហការំ គវេសន្តោ    ទុក្ខា ជាតិ បុនប្បុនំ ។**

*កាលតថាគតមិនទាន់បានជួបប្រទះ (ពោធិញ្ញាណ រវល់តែ) ស្វះ- ស្វែងរកជាងផ្ទះគឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន សេចក្តីកើត ជាទុក្ខរឿយៗ ។*

**គហការក ទិដ្ឋោសិ      បុន គេហំ ន កាហសិ**

**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ**

**វិសង្ខារគតំ ចិត្តំ      តណ្ហានំ ខយមជ្ឈគា ។**

*នៃជាងផ្ទះ! អ្នកឯងធ្វើផ្ទះគឺអត្តភាព តថាគតឃើញហើយ អ្នកនឹង ធ្វើផ្ទះ(របស់តថាគត) ទៀត មិនបានឡើយ ឆ្អឹងជំនីរគឺកិលេសរបស់អ្នក ទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះគឺអវិជ្ជា តថាគតកម្ចាត់*

*ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វានដែលមានសង្ខារប្រាស ហើយ តថាគតបានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។*

**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**
**ជិណ្ណកោញ្ចាវ ឈាយន្តិ ខីណមច្ឆេវ បល្លលេ ។**

*ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យក្នុងកាលខ្លួននៅជាកំលោះក្រមុំ រមែងសញ្ចប់សញ្ចឹង ដូចសត្វក្រៀលចាស់សំកុកនៅក្នុងភក់ដែលអស់ត្រីហើយ ។*

**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**
**សេន្តិ ចាបាតិខីណាវ បុរាណានិ អនុត្ថុនំ ។**

*ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យក្នុងកាលខ្លួននៅកំលោះក្រមុំ រមែងដេកថ្ងូរ សោកស្តាយទ្រព្យចាស់ទាំងឡាយ ដូចព្រួញដែលផុតចាកខ្សែបន្លោះដូច្នោះ ។*

## អត្តវគ្គទី១២

**អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ**
**តិណ្ណំ អញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ។**

*បើបណ្ឌិតដឹងថា ខ្លួនជាទីស្រលាញ់ គួររក្សាខ្លួននោះឲ្យល្អ គួរស្ងួនគ្រងខ្លួនទុកក្នុងវ័យទាំង៣ វ័យណាមួយ ។*

**អត្តានមេវ បឋមំ បដិរូបេ និវេសយេ**

**អថញ្ញមនុសាសេយ្យ ន កិលិស្សេយ្យ បណ្ឌិតោ ៕**

*បណ្ឌិត គួរតម្កល់ខ្លួនទុកក្នុងគុណដ៏សមគួរជាមុនសិន ហើយសឹមប្រៀនប្រដៅអ្នកដទៃជាខាងក្រោយ (ធ្វើយ៉ាងនេះ) នឹងមិនលំបាកឡើយ ។*

**អត្តានញ្ចេ តថា កយិរា យថញ្ញមនុសាសតិ**

**សុទន្តោ វត ទមេថ អត្តា ហិ កិរ ទុទ្ទមោ ៕**

*បុគ្គលប្រៀនប្រដៅអ្នកដទៃ យ៉ាងណា ត្រូវធ្វើខ្លួនឲ្យបានយ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថាខ្លួនកម្រទូន្មានបានពេកណាស់ ។*

**អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា**

**អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ ៕**

*ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាននូវទីពឹង ដែលគេបានដោយកម្រ*

**សុករានិ អសាធូនិ អត្តនោ អហិតានិ ច**

**យំ វេ ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ ៕**

*កម្មទាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងនោះ ជនពាលធ្វើបានដោយងាយ កម្មណាជាប្រយោជន៍ផង ល្អផង កម្មនោះឯង ជនពាលធ្វើបានដោយលំបាក ។*

**យោ សាសនំ អរហតំ អរិយានំ ធម្មជីវិនំ**

**បដិក្កោសតិ ទុម្មេធោ ទិដ្ឋឹ និស្សាយ បាបិកំ**

**ផលានិ កណ្ឌកស្សេវ អត្តឃញ្ញាយ ផល្លតិ ។**

*បុគ្គលណាអប្បប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ហាមឃាត់សាសនារបស់ព្រះអរហន្តទាំងឡាយដ៏ប្រសើរ រស់នៅដោយធម៌ ការហាមឃាត់របស់បុគ្គលនោះ រមែងចេញផល ដើម្បីសម្លាប់ខ្លួន ដូចផ្លែឫស្សីដូច្នោះ ។*

**អត្តនា ច កតំ បាបំ អត្តនា សង្កិលិស្សតិ**

**អត្តនា អកតំ បាបំ អត្តនា ច វិសុជ្ឈតិ**

**សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។**

*អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើបាបខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង សេចក្តីបរិសុទ្ធិនិងមិនបរិសុទ្ធិ មានចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃ ឲ្យបរិសុទ្ធមិនបានឡើយ ។*

**អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ**

**អត្តទត្ថមភិញ្ញាយ សទត្ថបសុតោ សិយា ។**

*បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន(នោះ) ។*

# លោកវគ្គទី១៣

**ហីនំ ធម្មំ ន សេវេយ្យ  បមាទេន ន សំវសេ**
**មិច្ឆាទិដ្ឋឹ ន សេវេយ្យ  ន សិយា លោកវឌ្ឍនោ ។**

*បុគ្គលមិនគួរសេពធម៌ថោកទាប មិនគួរនៅដោយសេចក្តីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សបង្អៀតលោក ។*

**ធម្មំ ចរេ សុចរិតំ  ន តំ ទុច្ចរិតំ ចរេ**
**ធម្មចារី សុខំ សេតិ  អស្មឹ លោកេ បរម្ហិ ច ។**

*បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។*

**ឯថ បស្សថិមំ លោកំ  ចិត្តំ រាជរថូបមំ**
**យត្ថ ពាលា វិសីទន្តិ  នត្ថិ សង្គោ វិជានតំ ។**

*អ្នកទាំងឡាយ ចូរមកមើលលោកនេះ ដ៏ត្រកាល ដូចជារាជរថ, ជនពាលទាំងឡាយ រមែងលិចលង់ក្នុងលោកណា សេចក្តីជាប់ចំពាក់ក្នុងលោកនោះ រមែងមិនមានដល់ជនជាបណ្ឌិតទាំងឡាយដែលដឹងច្បាស់ទេ ។*

**យោ ច បុព្វេ បមជ្ជិត្វា  បច្ឆា សោ នប្បមជ្ជតិ**
**សោមំ លោកំ បភាសេតិ  អព្ភា មុត្តោវ ចន្ទិមា ។**

បុគ្គលណា ប្រមាទហើយក្នុងកាលមុន លុះកាលជាខាងក្រោយ គេមិនប្រមាទវិញ បុគ្គលនោះឈ្មោះថា ញ៉ាំងខន្ធាទិលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទរះផុតចាកពពក ។

**យស្ស បាបំ កតំ កម្មំ កុសលេន បិធីយតិ**
**សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ៕**

បុគ្គលណា ធ្វើអំពើបាបហើយ បិទខ្ទប់អំពើបាបនោះដោយកុសលគឺអរហត្តមគ្គបាន បុគ្គលនោះឈ្មោះថា ញ៉ាំងខន្ធាទិលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទរះផុតចាកពពក ។

**អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ**
**សកុណោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ ៕**

លោកិយមហាជននេះ ជាមនុស្សងងឹត បណ្ដាជនទាំងនេះ ជនតិចគ្នាដែលឃើញច្បាស់ (ត្រៃលក្ខណ៍) ជនតិចគ្នា ដែលទៅកាន់ឋានសួគ៌ ដូចសត្វស្លាប (ដែលជាប់សំណាញ់របស់ព្រានហើយ) តិចណាស់ដែលរួចអំពីសំណាញ់ ដូច្នោះ ។

**ឯកំ ធម្មំ អតីតស្ស មុសាវាទិស្ស ជន្តុនោ**
**វិតិណ្ណបរលោកស្ស នត្ថិ បាបំ អការិយំ ៕**

បុគ្គលប្រព្រឹត្តកន្លង (ពាក្យសច្ចៈ) ដែលជាធម៌ឯក និយាយតែពាក្យកុហក មានបរលោកលះចោលហើយ ឈ្មោះថា មិនធ្វើអំពើបាបមិនមែនឡើយ ។

**ន វេ កទរិយា ទេវលោកំ វជន្តិ**
**ពាលា ហវេ នប្បសំសន្តិ ទានំ**
**ធីរោ ច ទានំ អនុមោទមានោ**
**តេនេវ សោ ហោតិ សុខី បរត្ថ ។**

*បុគ្គលកំណាញ់ស្វិតស្វាញមិនបានទៅកាន់ទេវលោកទេ ជនពាលទាំងឡាយ មិនសរសើរទានឡើយ ចំណែកអ្នកប្រាជ្ញតែងអនុមោទនាទាន ព្រោះហេតុនោះ លោកតែងបានសេចក្ដីសុខក្នុងលោកខាងមុខ ។*

**បថវ្យា ឯករជ្ជេន សគ្គស្ស គមនេន វា**
**សព្វលោកាធិបច្ចេន សោតាបត្តិផលំ វរំ ។**

*សោតាបត្តិផល ជាគុណជាតដ៏ប្រសើរ ជាងភាពនៃឯករាជ្យលើផែនដីផង ជាងដំណើរទៅកាន់ឋានសួគ៌ផង ជាងភាពជាធំក្នុងលោកទាំងមូលផង ។*

# ពុទ្ធវគ្គទី១៤

**កិច្ឆោ មនុស្សបដិលាភោ កិច្ឆំ មច្ចាន ជីវិតំ**
**កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ ។**

*ការត្រលប់បានអត្តភាពជាមនុស្ស បានដោយកម្រ ការរស់នៅរបស់សត្វទាំងឡាយ បានដោយកម្រ ការស្តាប់ធម៌របស់សប្បុរស បានដោយកម្រ ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ បានដោយកម្រ ។*

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា**

**សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។**

*ការមិនធ្វើបាបទាំងពួង ការញុំាងកុសលឲ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ ។*

**ខន្តិ បរមំ តបោ តីតិក្ខា**

**និព្វានំ បរមំ វទន្តិ ពុទ្ធា**

**ន ហិ បព្វជិតោ បរូបឃាតី**

**សមណោ ហោតិ បរំ វិហេឋយន្តោ ។**

*ខន្តិ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយ តែងពោលថា ព្រះនិព្វានជាធម្មជាតដ៏ឧត្តម បុគ្គលដែលសម្លាប់សត្វដទៃ មិនឈ្មោះថាបព្វជិតទេ បុគ្គលដែលបៀតបៀនសត្វដទៃ ក៏មិនឈ្មោះថាសមណៈឡើយ ។*

**អនូបវាទោ អនូបឃាតោ ឃាតិមោក្ខេ ច សំវរោ**

**មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ**

**អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ ។**

*ការមិនតិះដៀល(អ្នកដទៃ)១ ការមិនបៀតបៀន(អ្នកដទៃ)១ ការសង្រួមក្នុងបាតិមោក្ខ១ ភាពជាអ្នកដឹងប្រមាណក្នុងភត្ត១ ការដេកនិងអង្គុយក្នុងទីស្ងាត់១ ការព្យាយាមក្នុងអធិចិត្ត១ នុ៎ះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។*

**ន កហាបណវស្សេន កិត្តិ កាមេសុ វិជ្ជតិ**
**អប្បស្សាទា ទុក្ខា កាមា ឥតិ វិញ្ញាយ បណ្ឌិតោ**
**អបិ ទិព្វេសុ កាមេសុ រតឹ សោ នាធិគច្ឆតិ**
**តណ្ហក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោ ។**

*ការស្កប់ស្កល់ ក្នុងកាមទាំងឡាយ រមែងមិនមានព្រោះកហាបណៈ (ដែលធ្លាក់ចុះ) ដូចទឹកភ្លៀងទេ កាមទាំងឡាយមានសុខតិច មានទុក្ខច្រើន អ្នកប្រាជ្ញដឹងច្បាស់ យ៉ាងនេះហើយ លោកមិនបានត្រេកអរក្នុងកាមទាំងឡាយ សូម្បីជាទិព្វឡើយ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធរមែងជាអ្នកត្រេកអរក្នុងធមិជាគ្រឿងអស់តណ្ហា ។*

**ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច**
**អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា**
**នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ**
**នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។**

*មនុស្សទាំងឡាយ ច្រើននាក់ ត្រូវភ័យគំរាមហើយ តែងយកភ្នំ អារាមនិងរុក្ខចេតិយជាទីពឹង, ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ក្សេមទេ*

ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ឧត្តមទេ បុគ្គលអាស្រ័យនូវទីពឹងនេះ ហើយ រមែងមិនរួចស្រឡះចាកទុក្ខទាំងពួងឡើយ ។

**យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ**
**ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ**
**ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ**
**អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ**
**ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ**
**ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។**

លុះតែបុគ្គលណា យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ឃើញច្បាស់នូវអរិយសច្ចៈទាំង៤ គឺទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ និរោធសច្ចកន្លងទុក្ខ ១ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វានដែលជាទីរម្ងាប់ទុក្ខ ១ ដោយប្រាជ្ញាដ៏ប្រពៃ នេះឯងជាទីពឹងដ៏ក្សេម នេះឯងជាទីពឹងដ៏ឧត្តម បុគ្គលអាស្រ័យទីពឹងនេះ(ហើយ) រមែងរួចស្រឡះចាក ទុក្ខទាំងពួងបាន ។

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា**
**សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។**

ការកើតឡើងនៃព្រះពុទ្ធ ជាសុខ ការសម្តែងព្រះសទ្ធម្ម ជាសុខ សេចក្តីព្រមព្រៀងគ្នានៃពួក (សង្ឃឬពួកក្រុម) ជាសុខ សេចក្តីព្រមព្រៀងគ្នា របស់អ្នកមានតបធម៌ទាំងឡាយ ជាសុខ ។

**បូជារហេ បូជយតោ ពុទ្ធេ យទិ ច សាវកេ**
**បបញ្ចសមតិក្កន្តេ តិណ្ណសោកបរិទ្ទវេ**
**តេ តាទិសេ បូជយតោ និព្វុតេ អកុតោភយេ**
**ន សក្កា បុញ្ញំ សង្ខាតុំ ឥមេត្តមបិ កេនចិ ។**

*កាលបុគ្គលបូជា ដល់បូជារហបុគ្គល គឺព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ដែលកន្លងផុតបបញ្ចធម៌ ដែលកន្លងផុតសេចក្តីសោកនិងខ្សឹកខ្សួល ឬកាលបូជាដល់បូជារហបុគ្គលទាំងនោះ ដែលប្រកបដោយតាទិគុណ លោកមិនមានភ័យអំពីទីណា សូម្បីនិព្វានទៅហើយ បុគ្គលណាមួយមិនអាចរាប់បុណ្យថា បុណ្យនេះមានប្រមាណប៉ុណ្ណេះបានឡើយ ។*

## សុខវគ្គទី១៥

**ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ**
**ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។**

*បុគ្គលអ្នកឈ្នះ តែងរងនូវពៀរ បុគ្គលអ្នកចាញ់ តែងដេកជាទុក្ខ ចំណែកបុគ្គលលះបង់ការឈ្នះនិងការចាញ់ចេញហើយ ជាអ្នកស្ងប់រម្ងាប់ ទើបដេកជាសុខ ។*

**នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ កលិ**
**នត្ថិ ខន្ធសមា ទុក្ខា នត្ថិ សន្តិ បរំ សុខំ ។**

ភ្លើងស្មើដោយរាគៈ មិនមាន ទោសកំហុសស្មើដោយទោសៈ មិនមាន ទុក្ខទាំងឡាយស្មើដោយខន្ធមិនមាន សុខក្រៅពីសេចក្តីស្ងប់ មិនមាន ។

**ជិឃច្ឆា បរមា រោគា សង្ខារា បរមា ទុក្ខា**
**ឯតំ ញត្វា យថាភូតំ និព្វានំ បរមំ សុខំ ។**

សេចក្តីស្រេកឃ្លាន ជារោគយ៉ាងក្រៃលែង សង្ខារទាំងឡាយ ជាទុក្ខយ៉ាងក្រៃលែង (អ្នកប្រាជ្ញ) ដឹងច្បាស់សេចក្តីនុ៎ះ តាមពិតហើយ (រមែងធ្វើឲ្យច្បាស់)នូវព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

**អារោគ្យបរមា លាភា សន្តុដ្ឋិបរមំ ធនំ**
**វិស្សាសបរមា ញាតី និព្វានំ បរមំ សុខំ ។**

ការមិនមានរោគ ជាលាភយ៉ាងក្រៃលែង សេចក្តីសន្តោសជាទ្រព្យយ៉ាងក្រៃលែង សេចក្តីស្និទ្ធស្នាល ជាញាតិយ៉ាងក្រៃលែង ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ។

**សាធុ ទស្សនមរិយានំ សន្និវាសោ សទា សុខោ**
**អទស្សនេន ពាលានំ និច្ចមេវ សុខី សិយា ។**

ការជួបប្រទះ ព្រះអរិយបុគ្គលទាំងឡាយ ជាការល្អ ការនៅរួមជាមួយព្រះអរិយបុគ្គលទាំងឡាយ ជាហេតុឲ្យកើតសេចក្តីសុខសព្វកាល បុគ្គលគប្បីមានសេចក្តីសុខអស់កាលជានិច្ចបាន ព្រោះមិនជួបប្រទះបុគ្គលពាលទាំងឡាយ ។

**ពាលសង្គតចារី ហិ ទីឃមទ្ធាន សោចតិ**
**ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វសោ ។**

*បុគ្គលអ្នកប្រព្រឹត្តសមគប់ដោយជនពាល រមែងសោកស្តាយអស់កាលយូរអង្វែង ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខសព្វកាល ។*

# បិយវគ្គទី១៦

**បិយតោ ជាយតី សោកោ បិយតោ ជាយតី ភយំ**
**បិយតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

*សេចក្តីសោកកើតអំពីសេចក្តីស្រលាញ់ ភ័យកើតអំពីសេចក្តីស្រលាញ់ កាលបើរួចស្រឡះចាក សេចក្តីស្រលាញ់ហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។*

**បេមតោ ជាយតី សោកោ បេមតោ ជាយតី ភយំ**
**បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

*សេចក្តីសោកកើតអំពីសេចក្តីស្រលាញ់ ភ័យកើតអំពីសេចក្តីស្រលាញ់ កាលបើរួចស្រឡះចាក សេចក្តីស្រលាញ់ហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។*

**រតិយា ជាយតី សោកោ រតិយា ជាយតី ភយំ**
**រតិយា វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

*សេចក្ដីសោកកើតអំពីតម្រេក ភ័យកើតអំពីតម្រេក កាលបើរួចស្រឡះចាកតម្រេកហើយ សេចក្ដីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។*

**កាមតោ ជាយតី សោកោ  កាមតោ ជាយតី ភយំ**
**កាមតោ វិប្បមុត្តស្ស  នត្ថិ សោកោ កុតោ ភយំ ។**

*សេចក្ដីសោកកើតអំពីកាម ភ័យកើតអំពីកាម កាលបើរួចស្រឡះចាកកាមហើយ សេចក្ដីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។*

**តណ្ហាយ ជាយតី សោកោ  តណ្ហាយ ជាយតី ភយំ**
**តណ្ហាយ វិប្បមុត្តស្ស  នត្ថិ សោកោ កុតោ ភយំ ។**

*សេចក្ដីសោកកើតអំពីតណ្ហា ភ័យកើតអំពីតណ្ហា កាលបើរួចស្រឡះចាកតណ្ហាហើយ សេចក្ដីសោកក៏លែងមាន ភ័យនឹងមានមកពីណា*

**ចិរប្បវាសឹ បុរិសំ  ទូរតោ សោត្ថិមាគតំ**
**ញាតី មិត្តា សុហជ្ជា ច  អភិនន្ទន្តិ អាគតំ**
**តថេវ កតបុញ្ញម្បិ  អស្មា លោកា បរំ គតំ**
**បុញ្ញានិ បដិគណ្ហន្តិ  បិយំ ញាតីវ អាគតំ ។**

*ពួកញាតិក្ដី មិត្រក្ដី សម្លាញ់ក្ដី រមែងត្រេកអរនឹងបុរសដែលឃ្លាតគ្នាអស់កាលយូរ មកអំពីចម្ងាយដោយសួស្ដី មកដល់ហើយ យ៉ាងណាមិញ បុណ្យទាំងឡាយតែងទទួលបុគ្គល ដែលបានធ្វើបុណ្យ ច្យុតអំពីមនុស្ស*

លោកនេះ ទៅកាន់លោកខាងមុខ ដូចញាតិទាំងឡាយទទួលបុរសជាទីស្រឡាញ់ទើបមកដល់ ដូច្នោះឯង ។

## ភោធវគ្គទី១៧

**យោ វេ ឧប្បតិតំ កោធំ រថំ ភន្តំវ ធារយេ**
**តមហំ សារថឹ ព្រូមិ រស្មិគ្គាហោ ឥតរោ ជនោ ។**

បុគ្គលឃាត់សេចក្តីក្រោធដែលកើតឡើងហើយ ដូចសារថីទប់រថដែលកំពុងលឿនបាន តថាគតហៅបុគ្គលនោះថាជាសារថី ជនក្រៅពីនេះគ្រាន់តែជាអ្នកកាន់ខ្សែបរ (មិនមែនសារថីឡើយ) ។

**អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ**
**ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។**

បុគ្គលគប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្តីមិនក្រោធ គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្ចាញ់មនុស្សកំណាញ់ ដោយការឲ្យ គប្បីផ្ចាញ់មនុស្សនិយាយពាក្យមិនពិត ដោយពាក្យពិត ។

**អហឹសកា យេ មុនយោ និច្ចំ កាយេន សំវុតា**
**តេ យន្តិ អច្ចុតំ ឋានំ យត្ថ គន្ត្វា ន សោចរេ ។**

ជនទាំងឡាយណា ជាអ្នកប្រាជ្ញ[១] មិនបៀតបៀនសត្វដទៃ សង្រួមហើយដោយកាយទ្វារ (ជាដើម) ជានិច្ច ជនទាំងឡាយនោះ រមែងទៅកាន់ស្ថានដ៏មិនប្រែប្រួល ជាស្ថានដែលគេទៅដល់ហើយ តែងមិនសោកស្តាយ ។

## មលវគ្គទី១៨

**បណ្ឌុបលាសោវទានិសិ**

**យមបុរិសាបិ ច តេ ឧបដ្ឋិតា**

**ឧយ្យោគមុខេ ច តិដ្ឋសិ**

**បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។**

ឥឡូវនេះ ខ្លួនអ្នកដូចស្លឹកឈើទុំហើយ ទាំងពួកបុរសរបស់យមរាជ ប្រាកដដល់អ្នកហើយ ខ្លួនអ្នកតាំងនៅក្នុងមាត់សេចក្តីវិនាស សូម្បីស្បៀងគឺកុសលរបស់អ្នក ក៏មិនទាន់មានឡើយ ។

**សោ ករោហិ ទីបមត្តនោ**

**ខិប្បំ វាយម បណ្ឌិតោ ភវ**

**និទ្ធន្តមលោ អនង្គណោ**

**ទិព្វំ អរិយភូមិមេហិសិ ។**

---

១-សំដៅយកសេក្ខមុនី ដែលសម្រេចមគ្គផល ដោយមានេយ្យប្បដិបទា ។

អ្នកចូរធ្វើកុសលជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក(ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកម្ចាត់បង់មន្ទិលបាន មិនមានទីទួលគឺកិលេស នឹងដល់នូវភូមិរបស់ព្រះអរិយៈ ដូចជាទិព្វបាន ។

**ឧបនីតវយោ វទានិសិ**

**សម្បយាតោសិ យមស្ស សន្តិកំ**

**វាសោបិ ច តេ នត្ថិ អន្តរា**

**បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។**

ឥឡូវនេះ ខ្លួនអ្នកត្រូវជរាចូលដល់ហើយ ជាអ្នករៀបដំណើរទៅកាន់សម្នាក់យមរាជ មួយទៀត ទីសំចតក្នុងចន្លោះមិនមានដល់អ្នកទេ សូម្បីស្បៀងក៏មិនមានដល់អ្នក ។

**អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ**

**កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។**

អ្នកមានប្រាជ្ញា គួរកម្ចាត់បង់មន្ទិលរបស់ខ្លួន បន្តិចម្តង ៗ រាល់ ៗ ខណៈ ដោយលំដាប់ ដូចជាងមាសជម្រះស្នឹម ឬច្រែះរបស់មាសដូច្នោះ ។

**អយសា វ មលំ សមុដ្ឋិតំ**

**តទុដ្ឋាយ តមេវ ខាទតិ**

**ឯវំ អតិធោនចារិនំ**

**សានិ កម្មានិ នយន្តិ ទុគ្គតិំ ។**

ព្រោះកើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញ យ៉ាងណាមិញ កម្មទាំងឡាយរបស់ខ្លួន តែងនាំបុគ្គលអ្នកប្រព្រឹត្តកន្លងបញ្ញាជាគ្រឿងជម្រះចិត្ត ឲ្យទៅកាន់ទុគ្គតិ ក៏យ៉ាងនោះឯង ។

**អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា**
**មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។**

មន្តទាំងឡាយ មានការមិនស្វាធ្យាយជាមន្ទិល ផ្ទះទាំងឡាយ មានការមិនថែទាំ ជាមន្ទិល សេចក្តីខ្ជិលជាមន្ទិលរបស់ពណ៌សម្បុរ សេចក្តីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា ។

**មលិត្ថិយា ទុច្ចរិតំ មច្ឆេរំ ទទតោ មលំ**
**មលា វេ បាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច**
**តតោ មលា មលតរំ អវិជ្ជា បរមំ មលំ**
**ឯតំ មលំ បហន្ត្វាន និម្មលា ហោថ ភិក្ខវោ ។**

ការប្រព្រឹត្តិអាក្រក់ ជាមន្ទិលរបស់ស្ត្រី សេចក្តីកំណាញ់ជាមន្ទិលរបស់អ្នកឲ្យ ធមិអាក្រក់ទាំងឡាយ ជាមន្ទិលក្នុងលោកនេះនិងលោកខាងមុខ ធម្មជាតជាមន្ទិលដ៏លើសលប់ ជាងមន្ទិលទាំងនោះ គឺអវិជ្ជាជាមន្ទិលដ៏ក្រៃលែង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរលះមន្ទិលទាំងនេះចេញ ចូរកុំជាអ្នកមានមន្ទិលឡើយ ។

**យោ បាណមតិមាបេតិ មុសាវាទញ្ច ភាសតិ**
**លោកេ អទិន្នំ អាទិយតិ បរទារញ្ច គច្ឆតិ**

**សុរាមេរយបានញ្ច យោ នរោ អនុយុញ្ជតិ**
**ឥធេវមេសោ លោកស្មឹ មូលំ ខណតិ អត្តនោ ។**

*ជនណាសម្លាប់សត្វផង និយាយកុហកផង កាន់យកវត្ថុដែលគេមិនបានឲ្យ ក្នុងលោកផង សេពប្រពន្ធរបស់អ្នកដទៃផង ជនណាផឹកសុរានិងមេរ័យផង ជននោះឯងឈ្មោះថា គាស់រម្លើងឫសគល់របស់ខ្លួន ក្នុងលោកនេះដោយពិត ។*

**នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ គហោ**
**នត្ថិ មោហសមំ ជាលំ នត្ថិ តណ្ហាសមា នទី ។**

*ភ្លើងស្មើដោយរាគៈ មិនមាន ការចាប់ស្មើដោយទោសៈ មិនមាន បណ្ដាញស្មើដោយមោហៈ មិនមាន ស្ទឹងស្មើដោយតណ្ហា មិនមាន ។*

## ធម្មដ្ឋវគ្គទី១៩

**ន តេន បណ្ឌិតោ ហោតិ យាវតា ពហុ ភាសតិ**
**ខេមី អវេរី អភយោ បណ្ឌិតោតិ បវុច្ចតិ ។**

*បុគ្គល ឈ្មោះថាបណ្ឌិត មិនមែនព្រោះហេតុត្រឹមតែចេះនិយាយច្រើនទេ លុះត្រាតែបុគ្គលដែលមានសេចក្ដីក្សេម មិនមានពៀរ មិនមានភ័យ ទើបហៅថា បណ្ឌិតបាន ។*

**ន តាវតា ធម្មធរោ    យាវតា ពហុ ភាសតិ**
**យោ ច អប្បម្បិ សុត្វាន    ធម្មំ កាយេន បស្សតិ**
**ស វេ ធម្មធរោ ហោតិ    យោ ធម្មំ នប្បមជ្ជតិ ៕**

*បុគ្គល មិនទាន់ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ព្រោះហេតុតែចេះនិយាយច្រើនទេ លុះត្រាតែបុគ្គលណាស្តាប់ពុទ្ធវចនៈ សូម្បីមានប្រមាណតិច ហើយឃើញធម៌ដោយនាមកាយគឺចិត្តបាន បុគ្គលនោះទើបឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ បុគ្គលណាមិនមើលងាយធម៌ បុគ្គលនោះឯងឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ ។*

**ន តេន ថេរោ ហោតិ    យេនស្ស បលិតំ សិរោ**
**បរិបក្កោ វយោ តស្ស    មោឃជិណ្ណោតិ វុច្ចតិ ៕**

*បុគ្គលមានក្បាលស្កូវហើយ ដោយហេតុណា ឈ្មោះថាជាថេរៈ ដោយហេតុនោះ មិនទាន់បានទេ វ័យរបស់បុគ្គលនោះ ចាស់ជ្រុលហើយ ហៅថា ចាស់ដោយមោឃៈ ។*

**យម្ហិ សច្ចញ្ច ធម្មោ ច    អហឹសា សញ្ញមោ ទមោ**
**ស វេ មន្តមលោ ធីរោ    សោ ថេរោតិ បវុច្ចតិ ៕**

*លុះត្រាតែសច្ចៈផង ធម៌ផង ការមិនបៀតបៀនផង ការសង្រួមផង ការទូន្មានខ្លួនផង មានក្នុងបុគ្គលណា បុគ្គលនោះឯងជាអ្នកមានមន្ទិលខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថា ថេរៈ ។*

# មគ្គវគ្គទី២០

**សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**

*កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងមិនទៀងដូច្នេះ កាលណោះ រមែងនឿយណាយក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។*

**សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**

*កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងនាំមកនូវសេចក្តីទុក្ខដូច្នេះ កាលណោះ រមែងនឿយណាយក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។*

**សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**

*កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា ធម៌ទាំងពួងមិនមែនជារបស់ខ្លួនដូច្នេះ កាលណោះ រមែងនឿយណាយក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។*

**តំ បុត្តបសុសម្មត្តំ ព្យាសត្តមនសំ នរំ**
**សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។**

*មច្ចុ គឺសេចក្តីស្លាប់ តែងនាំយកនរជន អ្នកស្រវឹងជ្រប់ក្នុងកូននិង សត្វចិញ្ចឹម មានចិត្តជាប់ចំពាក់ ក្នុងអារម្មណ៍ផ្សេងៗនោះ ដូចជំនន់ទឹកធំនាំ យកអ្នកស្រុកកំពុងដេកលក់ទៅ ។*

**ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា**
**អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា**
**ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ**
**និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។**

*បុគ្គល កាលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយមិនមាន ដើម្បីជាទីពឹង បិតា ក៏មិនមាន ទាំងផៅពង្ស ក៏មិនមានដើម្បីជាទីពឹងឡើយ សេចក្តីទីពឹងក្នុងញាតិទាំងឡាយ ក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍ នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ជម្រះផ្លូវជាទីទៅ កាន់ព្រះនិព្វានឲ្យបាន ។*

# បកិណ្ណកវគ្គទី២១

**មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ**
**ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ ។**

*បើឃើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់សុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលឃើញសុខដ៏ធំទូលាយ គប្បីលះសុខល្មមប្រមាណ ចេញ ។*

**បរទុក្ខូបធានេន យោ  អត្តនោ សុខមិច្ឆតិ**
**វេរសំសគ្គសំសដ្ឋោ  វេរា សោ ន បរិមុច្ចតិ ។**

*ជនប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ដោយបង្កទុក្ខឲ្យអ្នកដទៃ ជននោះឈ្មោះថា ច្រឡូកច្របល់ហើយ ដោយការជាប់ចំពាក់គឺពៀរ រមែងមិនរួចចាកពៀរទេ ។*

**ទុប្បព្វជ្ជំ ទុរភិរមំ  ទុរាវាសា ឃរា ទុខា**
**ទុក្ខោសមានសំវាសោ  ទុក្ខានុបតិតទ្ធគូ**
**តស្មា ន ចទ្ធគូ សិយា ន ច ទុក្ខានុបតិតោ សិយា ។**

*ការចេញបួសបានដោយក្រ ការត្រេកអរត្រូវបានដោយក្រ ផ្ទះទាំងឡាយមានការនៅគ្រប់គ្រងដោយលំបាក ជាការក្រ ការនៅរួមដោយជនស្មើគ្នា(១) (ដែលមិនមានសេចក្តីកោតក្រែង)ជាការក្រ ជនអ្នកដើរផ្លូវឆ្ងាយគឺវដ្តៈ តែងត្រូវសេចក្តីទុក្ខធ្លាក់ជាប់តាម ព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយផង មិនគប្បីជាអ្នកត្រូវសេចក្តីទុក្ខធ្លាក់ជាប់តាមផង*

# និរយវគ្គទី២២

**អភូតវាទី និរយំ ឧបេតិ**
**យោ វាបិ កត្វា ន ករោមីតិ ចាហ**

*១-អាចារ្យខ្លះប្រែថា ការនៅរួមដោយជនមិនស្មើគ្នាគឺ ទុក្ខោ+អសមានសំវាសោ ។*

**ឧភោបិ តេ បេច្ច សមា ភវន្តិ**
**និហីនកម្មា មនុជា បរត្ថ ។**

*បុគ្គល ពោលពាក្យមិនពិត ឬបុគ្គលណាធ្វើ(អំពើអាក្រក់) ហើយ និយាយថាអញមិនធ្វើទេ (បុគ្គលនោះ) រមែងទៅកាន់នរក, ជនទាំងពីរនាក់ ដែលមានអំពើទាបថោក(ស្មើគ្នា)នោះ លុះលះលោកនេះទៅហើយ រមែងជាអ្នកស្មើគ្នា(ដោយគតិ) ក្នុងលោកខាងមុខទៀត ។*

**កាសាវកណ្ឋា ពហវោ បាបធម្មា អសញ្ញតា**
**បាបា បាបេហិ កម្មេហិ និរយន្តេ ឧបបជ្ជរេ ។**

*ពួកជនច្រើននាក់ ដែលមានកព័ន្ធព័ទ្ធ ដោយសំពត់កាសាវៈ តែ (ប្រព្រឹត្ត)ធម៌ដ៏លាមក មិនបានសង្រួម ពួកជនលាមកទាំងនោះ រមែងទៅ កើតក្នុងនរក ដោយសារកម្មទាំងឡាយដ៏លាមកនោះ ។*

**សេយ្យោ អយោគុឡោ ភុត្តោ តត្តោ អគ្គិសិខូបមោ**
**យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ រដ្ឋបិណ្ឌំ អសញ្ញតោ ។**

*បព្វជិតទ្រុស្តសីល សូវបរិភោគដុំដែកដែលកំពុងក្តៅ មានពណ៌ ដូចអណ្តាតភ្លើង ប្រសើរជាង, បព្វជិតទ្រុស្តសីល មិនសង្រួម បរិភោគដុំ បាយអ្នកដែន នឹងប្រសើរដូចម្តេចបាន ។*

**កុសោ យថា ទុគ្គហិតោ ហត្ថមេវានុកន្តតិ**
**សាមញ្ញំ ទុប្បរាមដ្ឋំ និរយាយុបកឌ្ឍតិ ។**

ស្បូវភ្លាំង ដែលបុគ្គលកាន់មិនចំណាប់រមែងលះដៃ យ៉ាងណាមិញ ភាពជាសមណៈ ដែលបព្វជិតកាន់មិនស៊ប់សួនហើយ រមែងទាញបព្វជិតនោះទៅនរក យ៉ាងនោះឯង ។

**អកតំ ទុក្កតំ សេយ្យោ បច្ឆា តបតិ ទុក្កតំ**
**កតញ្ច សុកតំ សេយ្យោ យំ កត្វា នានុតប្បតិ ។**

អំពើអាក្រក់ ដែលបុគ្គលមិនធ្វើ ប្រសើរជាង (ព្រោះថា) អំពើអាក្រក់រមែងធ្វើឲ្យក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ បុគ្គលធ្វើអំពើណាហើយ រមែងមិនក្តៅក្រហាយក្រោយ អំពើនោះជាអំពើល្អ បើបុគ្គលធ្វើហើយឈ្មោះថា បុគ្គលប្រសើរ ។

**អលជ្ជិតាយេ លជ្ជន្តិ លជ្ជិតាយេ ន លជ្ជរេ**
**មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។**

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងខ្មាសក្នុងហេតុដែលគេមិនត្រូវខ្មាស រមែងមិនខ្មាស ក្នុងហេតុដែលគេត្រូវខ្មាស សត្វទាំងនោះតែងទៅកាន់ទុគ្គតិ ។

**អវជ្ជេ វជ្ជមតិនោ វជ្ជេ ច អវជ្ជទស្សិនោ**
**មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។**

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញក្នុងហេតុដែលឥតទោស ថាជាហេតុមានទោសផង យល់ឃើញក្នុងហេតុដែលមានទោស ថាជាហេតុឥតមានទោសផង សត្វទាំងនោះតែងទៅកាន់ទុគ្គតិ ។

# នាគវគ្គទី២៣

**អប្បមាទរតា ហោថ សចិត្តមនុរក្ខថ**

**ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ ។**

*អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្ដីមិនប្រមាទ ចូររក្សាចិត្តរបស់ខ្លួន ចូរស្រង់ខ្លួនចាកភក់គឺកិលេស ដែលឆ្លងបានដោយកម្រ ដូចដំរីដែលជាប់នៅក្នុងភក់ស្រង់ខ្លួនឲ្យរួចបាន ។*

**សុខា មត្តេយ្យតា លោកេ អថោ បេត្តេយ្យតា សុខា**

**សុខា សាមញ្ញតា លោកេ អថោ ព្រហ្មញ្ញតា សុខា ។**

*សេចក្ដីប្រតិបត្តិល្អក្នុងមាតា នាំសេចក្ដីសុខមកឲ្យក្នុងលោក ម្យ៉ាងទៀត សេចក្ដីប្រតិបត្តិល្អក្នុងបិតា នាំសេចក្ដីសុខមកឲ្យ សេចក្ដីប្រតិបត្តិល្អក្នុងសមណៈ នាំសេចក្ដីសុខមកឲ្យក្នុងលោក ម្យ៉ាងទៀត សេចក្ដីប្រតិបត្តិល្អក្នុងព្រាហ្មណ៍ នាំសេចក្ដីសុខមកឲ្យ ។*

**សុខំ យាវ ជរា សីលំ សុខា សទ្ធា បតិដ្ឋិតា**

**សុខោ បញ្ញាបដិលាភោ បាបានំ អករណំ សុខំ ។**

*សីលនាំសេចក្ដីសុខមកឲ្យ ដរាបដល់ចាស់ជរា សទ្ធាដែលបុគ្គលតម្កល់ស៊ប់ហើយ នាំសេចក្ដីសុខមកឲ្យ ការបានប្រាជ្ញា នាំសេចក្ដីសុខមកឲ្យ ការមិនធ្វើបាបទាំងឡាយ នាំសេចក្ដីសុខមកឲ្យ ។*

# តណ្ហាវគ្គទី២៤

**យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ**

**ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ**

**ឯវម្បិ តណ្ហានុសយេ អនូហតេ**

**និព្វត្តតី ទុក្ខមិទំ បុនប្បុនំ ។**

*កាលបើឫសឈើមិនមានសេចក្ដីអន្តរាយ នៅមាំមួនទេ ដើមឈើទុកជាកាប់ចោលហើយ ក៏តែងដុះឡើងទៀតបាន មានឧបមាដូចម្ដេចមិញ កាលបើតណ្ហានុស័យ បុគ្គលកម្ចាត់មិនទាន់បានហើយ ទុក្ខ (មានជាតិទុក្ខជាដើម)នេះ ក៏តែងកើតរឿយៗ មានឧបមេយ្យដូច្នោះឯង ។*

**តសិណាយ បុរក្ខតា បជា**

**បរិសប្បន្តិ សសោវ ពាធិតោ**

**សញ្ញោជនសង្គសត្តា**

**ទុក្ខមុបេន្តិ បុនប្បុនំ ចិរាយ ។**

*ពួកសត្វដែលតណ្ហា ជាទីញ៉ាំងសត្វឲ្យតក់ស្លុត ក្រុងទុកហើយ តែងរន្ធត់ដូចទន្សាយដែលព្រានទាក់បានហើយដូច្នោះ ពួកសត្វដែលជាប់ក្នុងសំយោជនៈនិងសង្គធម៌ (ធម៌ជាគ្រឿងចំពាក់) តែងដល់នូវសេចក្ដីទុក្ខរឿយៗអស់កាលអង្វែង ។*

**យេ រាគរត្តានុបតន្តិ សោតំ**

**សយំ កតំ មក្កដកោវ ជាលំ**

**ឯតម្ហិ ឆេត្វាន វជន្តិ ធីរា**

**អនបេក្ខិនោ សព្វទុក្ខំ បហាយ ។**

*ពួកជនណា ត្រេកអរដោយអំណាចរាគៈ ពួកជននោះតែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាងទម្លាក់ខ្លួនចុះកាន់សំណាញ់ ដែលធ្វើហើយដោយខ្លួនឯង អ្នកប្រាជ្ញទាំងឡាយតែងកាត់ខ្សែតណ្ហានោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះទុក្ខទាំងពួងចេញទៅ ។*

**សព្វទានំ ធម្មទានំ ជិនាតិ**

**សព្វរសំ ធម្មរសោ ជិនាតិ**

**សព្វរតឹ ធម្មរតិ ជិនាតិ**

**តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។**

*ធម្មទានឈ្នះអាមិសទានទាំងពួង ធម្មរសឈ្នះរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ ឈ្នះសេចក្តីត្រេកអរទាំងពួង ការអស់តណ្ហា ឈ្នះទុក្ខទាំងពួង ។*

**ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ**

**ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ ។**

*ភោគៈទាំងឡាយ រមែងសម្លាប់បុគ្គលអប្បប្រាជ្ញា ប៉ុន្តែមិនសម្លាប់បុគ្គលអ្នកស្វែងរកត្រើយគឺព្រះនិព្វានទេ ឯបុគ្គលអប្បឥតប្រាជ្ញា រមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់បុគ្គលដទៃ ព្រោះចំណង់ក្នុងភោគៈ ។*

**តិណទោសានិ ខេត្តានិ   រាគទោសា អយំ បជា**

**តស្មា ហិ វីតរាគេសុ   ទិន្នំ ហោតិ មហប្ផលំ ។**

*ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់អ្នកមានរាគៈអស់ហើយ រមែងជាទានមានផលច្រើន ។*

**តិណទោសានិ ខេត្តានិ   ទោសទោសា អយំ បជា**

**តស្មា ហិ វីតទោសេសុ   ទិន្នំ ហោតិ មហប្ផលំ ។**

*ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានទោសៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់អ្នកមានទោសៈអស់ហើយ រមែងជាទានមានផលច្រើន ។*

**តិណទោសានិ ខេត្តានិ   ឥច្ឆាទោសា អយំ បជា**

**តស្មា ហិ វីតិច្ឆេសុ   ទិន្នំ ហោតិ មហប្ផលំ ។**

*ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានសេចក្ដីប្រាថ្នាជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់អ្នកមានសេចក្ដីប្រាថ្នាអស់ហើយ រមែងជាទានមានផលច្រើន ។*

## ភិក្ខុវគ្គទី២៥

**ធម្មារាមោ ធម្មរតោ   ធម្មំ អនុវិចិន្តយំ**

**ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ ៕**

*ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយៗ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។*

**មេត្តាវិហារី យោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ**
**អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ៕**

*ភិក្ខុណា នៅដោយអំណាចមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។*

**នត្ថិ ឈានំ អបញ្ញស្ស នត្ថិ បញ្ញា អឈាយិនោ**
**យម្ហិ ឈានញ្ច បញ្ញា ច ស វេ និព្វានសន្តិកេ ៕**

*ការពិនិត្យមិនមានដល់បុគ្គលអ្នកមិនមានប្រាជ្ញា ប្រាជ្ញាមិនមានដល់បុគ្គលអ្នកមិនពិនិត្យ ការពិនិត្យនិងប្រាជ្ញា មានក្នុងបុគ្គលណា បុគ្គលនោះឯងឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។*

**សន្តកាយោ សន្តវាចោ សន្តមនោ សុសមាហិតោ**
**វន្តលោកាមិសោ ភិក្ខុ ឧបសន្តោតិ វុច្ចតិ ៕**

*ភិក្ខុអ្នកមានកាយរម្ងាប់ហើយ មានវាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសៈក្នុងលោកខ្ជាក់ចោលហើយ ទើបតថាគតហៅថា អ្នកស្ងប់រម្ងាប់ ។*

**យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ**
**សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ៕**

ភិក្ខុណានៅកំលោះ ប្រឹងប្រែងក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែង ញុំាងលោកនេះឲ្យភ្លឺស្វាងបាន ដូចព្រះចន្ទដែលរះផុតអំពីពពក ។

# ព្រាហ្មណវគ្គទី២៦

**យទា ទ្វយេសុ ធម្មេសុ　　　បារគូ ហោតិ ព្រាហ្មណោ**
**អថស្ស សព្វេ សំយោគា　　　អត្ថំ គច្ឆន្តិ ជានតោ ។**

កាលណា ព្រាហ្មណ៍អ្នកដល់ត្រើយ ក្នុងធម៌ពីរប្រការគឺសមថៈនិង វិបស្សនា ក្នុងកាលនោះ កិលេស គ្រឿងប្រកបសត្វទុកទាំងអស់របស់ ព្រាហ្មណ៍អ្នកដឹងនោះ រមែងដល់នូវការតាំងនៅមិនបាន ។

**ទិវា តបតិ អាទិច្ចោ　　　រត្តិមាភាតិ ចន្ទិមា**
**សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ**
**អថ សព្វមហោរត្តិំ　　　ពុទ្ធោ តបតិ តេជសា ។**

ព្រះអាទិត្យរុងរឿងក្នុងវេលាថ្ងៃ　　ព្រះចន្ទរុងរឿងក្នុងវេលាយប់ ក្សត្រទ្រង់ប្រដាប់ពេញយសហើយ រមែងរុងរឿង, សមណព្រាហ្មណ៍អ្នក មានឈាន រមែងរុងរឿង ឯព្រះសម្ពុទ្ធ រមែងរុងរឿងដោយតេជះ រហូតថ្ងៃ និងយប់ទាំងអស់ ។

**វារិ បោក្ខរបត្តេវ　　　អារគ្គេរិវ សាសបោ**
**យោ ន លិម្បតិ កាមេសុ　　　តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មានចិត្តមិនបានជាប់នៅ ក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ។

**អសំសដ្ឋំ គហដ្ឋេហិ  អនាគារេហិ ចូភយំ**
**អនោកសារឹ អប្បិច្ឆំ  តមហំ ព្រូមិ ព្រាហ្មណំ ៕**

តថាគតហៅ បុគ្គលដែលមិនច្រឡំ ដោយជនទាំងឡាយពីរពួក គឺគ្រហស្ថ១ បព្វជិត១ ជាអ្នកត្រាច់ទៅដោយមិនមានសេចក្តីអាល័យ មានសេចក្តីប្រាថ្នាតិចនោះ ថាជាព្រាហ្មណ៍ ។

**យោធ កាមេ បហន្ត្វាន អនាគារោ បរិព្វជេ**
**កាមភវបរិក្ខីណំ  តមហំ ព្រូមិ ព្រាហ្មណំ ៕**

បុគ្គលណាក្នុងលោកនេះ បានលះបង់កាមទាំងឡាយ ជាអ្នកមិនមានផ្ទះ គេចចេញចាកកាមបាន តថាគតហៅបុគ្គលនោះ ដែលអស់កាមភពហើយ ថាជាព្រាហ្មណ៍ ។

**ហិត្វា មានុសកំ យោគំ  ទិព្វំ យោគំ ឧបច្ចគា**
**សព្វយោគវិសំយុត្តំ  តមហំ ព្រូមិ ព្រាហ្មណំ ៕**

បុគ្គលណា លះកិលេសជាគ្រឿងប្រកប ដែលជារបស់មនុស្សកន្លងកិលេសជាគ្រឿងប្រកប ដែលជារបស់ទិព្វបានហើយ តថាគតហៅបុគ្គលដែលផុតស្រឡះ ចាកកិលេសជាគ្រឿងប្រកបទាំងពួងនោះ ថាជាព្រាហ្មណ៍ ។

# បកិណ្ណកធម៌

## រតនគាថា

**ចិត្តី កតំ មហគ្ឃញ្ច អតុលំ ទុល្លភទស្សនំ**

**អនោមសត្តបរិភោគំ រតនំ តេន វុច្ចតិ ។**

*វត្ថុដែលធ្វើឲ្យគេរីករាយ មានតម្លៃច្រើន ថ្លឹងមិនបាន ឃើញបាន ដោយលំបាក មិនជាការបរិភោគរបស់សត្វអ្នកថោកទាប ដោយហេតុនោះ ទើបហៅថា រតនៈ ។*

**ពុទ្ធោតិ វចនំ សេដ្ឋំ ពុទ្ធោតិ បទមុត្តមំ**

**នត្ថិ តេន សមំលោកេ អញ្ញំ សោតរសាយនំ ។**

*ពាក្យថា ព្រះពុទ្ធ ជាពាក្យដ៏ប្រសើរបំផុត បទថា ព្រះពុទ្ធ ជាបទដ៏ខ្ពង់ខ្ពស់បំផុត ពាក្យនិងបទដទៃដែលពីរោះដល់ត្រចៀក ស្មើដោយពាក្យនិងបទនោះ ក្នុងលោក មិនមានឡើយ ។*

**ធម្មោតិ វចនំ សេដ្ឋំ ធម្មោតិ បទមុត្តមំ**

**នត្ថិ តេន សមំលោកេ អញ្ញំ សោតរសាយនំ ។**

*ពាក្យថា ព្រះធម៌ ជាពាក្យដ៏ប្រសើរបំផុត បទថា ព្រះធម៌ ជាបទដ៏ខ្ពង់ខ្ពស់បំផុត ពាក្យនិងបទដទៃដែលពីរោះដល់ត្រចៀក ស្មើដោយពាក្យនិងបទនោះ ក្នុងលោក មិនមានឡើយ ។*

**សង្ឃោតិ វចនំ សេដ្ឋំ សង្ឃោតិ បទមុត្តមំ**

**នត្ថិ តេន សមំលោកេ អញ្ញំ សោតរសាយនំ ។**

ពាក្យថា ព្រះសង្ឃ ជាពាក្យដ៏ប្រសើរបំផុត បទថា ព្រះសង្ឃ ជាបទដ៏ខ្ពង់ខ្ពស់បំផុត ពាក្យនិងបទដទៃដែលពីរោះដល់ត្រចៀក ស្មើដោយពាក្យនិងបទនោះ ក្នុងលោក មិនមានឡើយ ។

**អប្បមាណោ ពុទ្ធោ** ព្រះពុទ្ធ ទ្រទ្រង់នូវព្រះគុណនឹងប្រមាណមិនបាន ។

**អប្បមាណោ ធម្មោ** ព្រះធម៌ ទ្រទ្រង់នូវព្រះគុណនឹងប្រមាណមិនបាន ។

**អប្បមាណោ សង្ឃោ** ព្រះសង្ឃទ្រទ្រង់នូវព្រះគុណនឹងប្រមាណមិនបាន ។

## មហាបរិនិព្វានសូត្រ

**ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា:**

**ឥមេ ខោ តេ ភិក្ខវេ ធម្មា មយា អភិញ្ញា ទេសិតា តេ វោ សាធុកំ ឧគ្គហេត្វា អាសេវិតព្វា ពហុលីកាតព្វា យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។**

ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់

ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណាដែលតថាគតសម្តែងហើយដោយបញ្ញាដ៏ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេពចម្រើន ធ្វើឲ្យរឿយៗ ដោយប្រការដូច្នោះ ។

សេយ្យថីទំ **ធម៌ទាំងនោះ តើដូចម្តេច ?**

**ធម៌ទាំងឡាយនោះគឺ:**

-ចត្តារោ សតិប្បដ្ឋានា: សតិប្បដ្ឋាន ៤

-ចត្តារោ សម្មប្បធានា: សម្មប្បធាន ៤

-ចត្តារោ ឥទ្ធិបាទា: ឥទ្ធិបាទ ៤

-បញ្ចិន្ទ្រិយានិ : ឥន្ទ្រិយ ៥

-បញ្ច ពលានិ : ពលៈ ៥

-សត្ត ពោជ្ឈង្គា : ពោជ្ឈង្គ ៧

-អរិយោ អដ្ឋង្គិកោ មគ្គោ: អរិយមគ្គអង្គ ៨ ។

**ទហរាបិ ច យេ វុឌ្ឍា**

**យេ ពាលា យេ ច បណ្ឌិតា**

**អឌ្ឍា ចេវ ទលិទ្ទា ច**

**សព្វេ មច្ចុបរាយនា ។**

*ពួកជនណាៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅពីខាងមុខ ។*

**យថាបិ កុម្ភការស្ស**
**កតំ មត្តិកភាជនំ**
**ខុទ្ទកញ្ច មហន្តញ្ច**
**យញ្ច បក្កំ យញ្ច អាមកំ**
**សព្វំ ភេទបរិយន្តំ**
**ឯវំ មច្ចាន ជីវិតំ ៕**

*ភាជន៍ដី ដែលស្មូនឆ្នាំងធ្វើហើយ ទោះបី តូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។*

-អថាបរំ ឯតទវោច សត្ថា

ព្រះសាស្តា ទ្រង់មានព្រះបន្ទូលដូច្នេះតទៅទៀតថាៈ

**បរិបក្កោ វយោ មយ្ហំ**
**បរិត្តំ មម ជីវិតំ**
**បហាយ វោ គមិស្សាមិ**
**កតំ មេ សរណមត្តនោ ៕**

វ័យរបស់តថាគតចាស់ហើយ ជីវិតរបស់តថាគតមានប្រមាណតិច តថាគតនឹងលះបង់អ្នកទាំងឡាយ ហើយទៅ ឯទីពឹងចំពោះខ្លួនតថាគតបានធ្វើទុកហើយ ។

**សេចក្តីមិនប្រមាទ**

**អប្បមត្តា សតីមន្តោ សុសីលា ហោថ ភិក្ខវោ**
**សុសមាហិតសង្កប្បា សចិត្តមនុរក្ខថ ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់នឹងល្អ ចូររក្សាចិត្តរបស់ខ្លួន ឲ្យបានរឿយៗចុះ ។

**យោ ឥមស្មឹ ធម្មវិនយេ អប្បមត្តោ វិហរិស្សតិ**
**បហាយ ជាតិសំសារំ ទុក្ខស្សន្តំ ករិស្សតីតិ ។**

ភិក្ខុណាមិនប្រមាទ ហើយនៅក្នុងធម្មវិន័យនេះ (ភិក្ខុនោះ) នឹងលះបង់ជាតិសង្សារ ហើយធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខបានមិនខាន ។

**ទ្រង់ប្រារព្ធចង្ហាន់នាយចុន្ទកម្មារបុត្ត**

**ទទតោ បុញ្ញំ បវឌ្ឍតិ**
**សំយមតោ វេរំ ន ចីយតិ**
**កុសលោ ច ជហាតិ បាបកំ**
**រាគទោសមោហក្ខយា និព្វុតោតិ ។**

បុណ្យរមែងចម្រើនដល់អ្នកឲ្យទាន វេរាមិនចម្រើនដល់បុគ្គលអ្នកសង្រួម បុគ្គលអ្នកឈ្លាស (បរិបូណ៌ដោយញាណ) រមែងលះបង់នូវអំពើលាមកបាន បុគ្គលនោះក៏បរិនិព្វាន ព្រោះអស់រាគៈ ទោសៈ មោហៈ ។

## ធម៌វិន័យជាសាស្តា

**យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច**

**ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា ។**

ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែងហើយបញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណើះឥតអំពីតថាគតទៅ ធម៌ និង វិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ ។

## ឱវាទចុងក្រោយ

អថខោ ភគវា ភិក្ខូ អាមន្តេសិ គ្រានោះព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថាៈ

**ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា**

**សង្ខារា អប្បមាទេន សម្បាទេថ ។**

ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយឲ្យបានដឹងថា សង្ខារទាំងឡាយមានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ.

# អានិសង្សបុណ្យ

**សុវណ្ណតា សុសរតា សុសណ្ឋានំ សុរូបតា**

**អាធិបច្ចំ បរិវារោ សព្វមេតេន លព្ភតិ ។**

*ភាពជាអ្នកមានសម្បុរផូរផង់ មានសំឡេងពីរោះ ទ្រង់ទ្រាយល្អ រូបល្អ ជាអធិបតី មានយសបរិវារ ផលទាំងអស់(នេះ) រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។*

**បទេសរជ្ជំ ឥស្សរិយំ ចក្កវត្តិសុខំ បិយំ**

**ទេវរជ្ជម្បិ ទិព្វេសុ សព្វមេតេន លព្ភតិ ។**

*ភាពជាស្តេចប្រទេសរាជ ឥស្សរិយយស សេចក្តីសុខរបស់ស្តេចចក្រពត្តិជាទីស្រលាញ់ ភាពជាស្តេចនៃទេវតាក្នុងទេពនិកាយ ផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។*

**មានុស្សិកា ច សម្បត្តិ ទេវលោកេ ច យា រតិ**

**យា ច និព្វានសម្បត្តិ សព្វមេតេន លព្ភតិ ។**

*សម្បត្តិជារបស់មនុស្សណាផង សេចក្តីត្រេកអរក្នុងទេវលោកណាផង សម្បត្តិគឺព្រះនិព្វានណាផង សម្បត្តិទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។*

**បដិសម្ភិទា វិមោក្ខា ច យា ច សាវកបារមី**

**បច្ចេកពោធិ ពុទ្ធភូមិ សព្វមេតេន លព្ភតិ ។**

បដិសម្ភិទា(៤) វិមោក្ខ(៨) សាវកបារមីញាណ បច្ចេកពោធិញ្ញាណ និងពុទ្ធភូមិណាៗ ឥដ្ឋផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។

**ឯវំ មហិទ្ធិកា ឯសា យទិទំ បុញ្ញសម្បទា**
**តស្មា ធីរា បសំសន្តិ បណ្ឌិតា កតបុញ្ញតំ ។**

បុញ្ញសម្បទានេះ ឲ្យសម្រេចប្រយោជន៍ដោយប្រការដូច្នេះ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយជាធីរជន ទើបសរសើរនូវភាពនៃបុគ្គលអ្នកមានបុណ្យធ្វើទុកហើយ។

## ធម្មុទ្ទេស៤យ៉ាង

**១- ឧបនីយតិ លោកោ អទ្ធុវោ**

សត្វលោក មិនទៀង តែងត្រូវជរានាំចូលទៅ (រកមរណៈ) ។

**២- អតាណោ លោកោ អនភិស្សរោ**

សត្វលោក មិនមានគ្រឿងការពារ មិនមានទីពឹងឡើយ ។

**៣- អស្សកោ លោកោ សព្វំ បហាយ គមនីយំ**

សត្វលោកសុទ្ធតែមិនមានអ្វីជារបស់ខ្លួន ត្រូវតែលះបង់នូវរបស់ទាំងពួង ។

**៤- ឩនោ លោកោ អតិត្តោ តណ្ហាទាសោ ។**

*សត្វលោក មានតែសេចក្ដីខ្វះខាត (ជានិច្ច) មិនចេះឆ្អែត សុទ្ធតែជាខ្ញុំរបស់តណ្ហា ។*

**-កាមេហិ លោកម្ហិ នហត្ថិ តិត្តិ**

*ឈ្មោះថា សេចក្ដីឆ្អែតឆ្អន់ដោយកាមទាំងឡាយ រមែងមិនមានក្នុងលោកឡើយ ។*

**សត្តោ បន គច្ឆតិ យេន កម្មំ ន មិយ្យមានំ**

**ធនមន្វេតិ កិញ្ចិ បុត្តា ច ទារា ច ធនញ្ច រដ្ឋំ ។**

*សត្វលោកប្រព្រឹត្តទៅតាមយថាកម្ម ទ្រព្យបន្តិចបន្តួច រមែងមិនទៅតាមបុគ្គលអ្នកស្លាប់ឡើយ ពួកកូន ប្រពន្ធ ទ្រព្យ និង ដែន ក៏មិនជាប់ទៅតាមទេ ។*

**នទីឃមាយុំ លភតេ ធនេន ន ចាបិ វិត្តេន ជរំ វិហំ**

**អប្បកញ្ហិនំ ជីវិតមាហុ ធីរា អសស្សតំ វិប្បរិណាមធម្មំ ។**

*បុគ្គលមិនបានអាយុវែង ព្រោះទ្រព្យទេ ទាំងមិនមែនលះបង់ជរាបានព្រោះទ្រព្យដែរ អ្នកប្រាជ្ញពោលថាជីវិតនេះតិចតួចណាស់ មិនទៀងទាត់ មានសភាពប្រែប្រួលជាធម្មតា ។*

**បស្សាមិ លោកេ សធនេ មនុស្សេ**

**លទ្ធាន វិត្តំ ន ទទន្តិ មោហា ។**

*អាត្មាបានឃើញនូវមនុស្សទាំងឡាយ បរិបូណ៌ដោយទ្រព្យសម្បត្តិក្នុងលោក (ពួកមនុស្សទាំងនោះ) លុះបានទ្រព្យគាប់ចិត្តហើយ មិនឲ្យ(ដល់បុគ្គលណាឡើយ) ព្រោះតែសេចក្តីវង្វេង ។*

**លទ្ធា ធនំ សន្និចយំ ករោន្តិ**

**ភិយ្យោ ច កាមេ អភិបត្ថយន្តិ ។**

*ពួកមនុស្សបានទ្រព្យហើយ ក៏ធ្វើនូវការសន្សំទុក ទាំងប្រាថ្នាក្នុងកាមដ៏លើសលប់ ។*

**រាជា បសយ្ហប្បថវឹ វិជេត្វា សសាគរន្តំ មហិមាវសន្តោ**

**ឱរំ សមុទ្ទស្ស អតិត្តរូបោ បារំ សមុទ្ទស្សបិ បត្ថយេថ ។**

*ព្រះរាជា ឈ្នះនូវផែនដី ដែលព្រះអង្គរឹបជាន់បានហើយ នៅគ្រប់គ្រងផែនដី មានសាគរជាទីបំផុត មានសភាពមិនឆ្អែតនឹងត្រើយសមុទ្រខាងអាយ ក៏ប្រាថ្នានូវត្រើយសមុទ្រខាងនាយ ។*

**អជ្ជេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ**

**ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា ។**

*ការព្យាយាម ជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯងអ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាដ៏ច្រើននោះមិនមានសោះឡើយ ។* (បិ.២៨/២)

**ឧបនីយតិ ជីវិតមប្បមាយុំ**

**ជរូបនីតស្ស ន សន្តិ តាណា**

**ឯតំ ភយំ មរណេ បេក្ខមានោ**

**បុញ្ញានិ កយិរាថ សុខាវហានិ ។**

*ជីវិតគឺអាយុ មានប្រមាណតិច ដែលជរាបញ្ជូនតៗគ្នា, ទីពឹងទាំងឡាយមិនមានដល់បុគ្គលដែលត្រូវជរាបញ្ជូនតៗគ្នាទេ កាលបើបុគ្គលឃើញភ័យក្នុងមរណៈនោះហើយ គួរតែធ្វើបុណ្យទាំងឡាយជាហេតុនាំមកនូវសេចក្តីសុខ ។*

**យោធ កាយេន សញ្ញមោ**

**វាចាយ ឧទ ចេតសា**

**តំ តស្ស បេតស្ស សុខាយ ហោតិ**

**យំ ជីវមានោ បករោតិ បុញ្ញំ ។**

*សេចក្តីសង្រួមដោយ កាយ វាចា ចិត្ត ណាតាំងពីឥឡូវនេះទៅ បុណ្យដែលកើតអំពីការសង្រួមនោះ រមែងប្រព្រឹត្តទៅដើម្បីជាសុខដល់បុគ្គលដែលទៅកាន់បរលោកនោះ (ព្រោះហេតុនោះ) បុគ្គលកាលរស់នៅគួរតែធ្វើបុណ្យ ។* (បិ.៤១/១៣៣)

**យថាបិ ឧទកេ ជាតំ បុណ្ឌរីកំ ច វឌ្ឍតិ**

**ន ឧបលិម្បតិ តោយេន សុចិគន្ធំ មនោរមំ**

**តថេវ លោកេ សុជាតោ ពុទ្ធោ លោកេ វិហរតិ**

**ន ឧបលិម្បតិ លោកេន តោយេន បទុមំ យថា ។**

*ឈូកសដែលដុះឡើង ចម្រើនឡើងក្នុងទឹក មានក្លិនល្អជាទីត្រេក-អរនៃចិត្ត មិនជាប់ដោយទឹក ដូចម្តេចមិញ ព្រះពុទ្ធទ្រង់កើតឡើងក្នុងលោក ក៏មិនជាប់ដោយលោកឡើយ ដូចផ្កាឈូក មិនជាប់ដោយទឹកដូច្នោះដែរ ។*

(បិ.៤៦/១៣៦)

**ការឲ្យទាន**

**អាទិត្តស្មឹ អគារស្មឹ យំ នីហរតិ ភាជនំ**

**តំ តស្ស ហោតិ អត្ថាយ នោ ច យំ តត្ថ ឌយ្ហតិ**

**ឯវមាទិត្តកោ លោកោ ជរាយ មរណេន ច**

**នីហរេថេវ ទានេន ទិន្នំ ហោតិ សុនីហតំ ។**

*បុគ្គល ជញ្ជូនភាជន៍ណាអំពីផ្ទះដែលភ្លើងកំពុងឆេះ ពុំនោះសោត ភ្លើងមិនទាន់ឆេះនូវវត្ថុណាក្នុងផ្ទះនោះ ភាជន៍និងវត្ថុនោះជាប្រយោជន៍នៃបុគ្គលនោះឯង (យ៉ាងណា) សត្វលោកដែលជរានិងមរណៈឆេះយ៉ាងនេះ ត្រូវតែនាំទ្រព្យចេញដោយទានកុំខាន (ព្រោះថា)ទានដែលបុគ្គលឲ្យហើយ ឈ្មោះថានាំចេញដោយល្អ ។*

**ទិន្នំ សុខផលំ ហោតិ នាទិន្នំ ហោតិ តំ តថា**

**ចោរា ហរន្តិ រាជានោ អគ្គិ ឌយ្ហតិ នស្សតិ**

**អថ អន្តេន ជហតិ សរីរំ សបរិគ្គហំ**

**ឯតទញ្ញាយ មេធាវី ភុញ្ជេថ ច ទទេថ ច**
**ទត្វា ច ភុត្វា ច យថានុភាវំ អនិន្ទិតោ**
**សគ្គមុបេតិ ឋានំ ។**

វត្ថុដែលបុគ្គលឲ្យហើយ ជាវត្ថុមានផលជាសុខ វត្ថុដែលបុគ្គលមិនឲ្យហើយ ជាវត្ថុមិនមានផលជាសុខទេ (ព្រោះថា) ពួកចោរតែងនាំទៅ ពួករាជការតែងរឹបយក ភ្លើងតែងឆេះវិនាសទៅ ពុំនោះសោត ពេលស្លាប់ទៅក៏រមែងលះបង់សរីរៈ និងទ្រព្យដែលខ្លួនធ្លាប់ហួងហែង, អ្នកប្រាជ្ញដឹងនូវសេចក្ដីនេះហើយ គប្បីបរិភោគផង ឲ្យទានផង បុគ្គលឲ្យទានទាំងបរិភោគឲ្យសមគួរតាមសភាពហើយ គេមិនដែលនិន្ទាទេ តែងបានទៅកើតក្នុងឋានសួគ៌ ។ (បិ.២៩/៧៨)

**អន្នទោ ពលទោ ហោតិ វត្ថទោ ហោតិ វណ្ណទោ**
**យានទោ សុខទោ ហោតិ ទីបទោ ហោតិ ចក្ខុទោ ។**

បុគ្គលឲ្យបាយ ឈ្មោះថាឲ្យកម្លាំង ឲ្យសំពត់ ឈ្មោះថាឲ្យពណ៌សម្បុរ ឲ្យយានជំនិះ ឈ្មោះថាឲ្យសេចក្ដីសុខ ឲ្យប្រទីប ឈ្មោះថាឲ្យចក្ខុ ។

**សោ ច សព្វទទោ ហោតិ យោ ទទាតិ ឧបស្សយំ**
**អមតន្ទទោ ច សោ ហោតិ យោ ធម្មមនុសាសតិ ។**

មួយទៀត បុគ្គលណា ឲ្យទីនៅអាស្រ័យ បុគ្គលនោះឈ្មោះថាឲ្យវត្ថុគ្រប់យ៉ាង បុគ្គលណាប្រៀនប្រដៅធម៌ បុគ្គលនោះឈ្មោះថាឲ្យព្រះនិព្វាន ។ (បិ.២៩/៨០)

**អារាមរោបា វនរោបា យេ ជនា សេតុការកា**
**បបញ្ច ឧទបានញ្ច យេ ទទន្តិ ឧបស្សយំ**
**តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ**
**ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោ ។**

*ជនណា ដាំច្បារឈើមានផ្កាផ្លែ ដាំច្បារឈើមានម្លប់ សង់ស្ពានសាងរោង ឲ្យទានទឹកទាំងជីកស្រះ ជនទាំងឡាយណា ឲ្យនូវទីសម្នាក់អាស្រ័យ បុណ្យរមែងចម្រើនមិនដាច់ ទាំងថ្ងៃទាំងយប់គ្រប់វេលា ដល់ជនទាំងឡាយនោះ ជនទាំងនោះ ឈ្មោះថាជាអ្នកតាំងនៅក្នុងធម៌ ឈ្មោះថាបរិបូណ៌ដោយសីល គួរទៅកាន់ឋានសួគ៌បាន ។* (បិ.២៩/៨៤)

## អំពីសីល

**បាតិមោក្ខំ វិសោធេន្តោ អប្បេវ ជីវិតំ ជហេ**
**បញ្ញត្តំ លោកនាថេន ន ភិន្ទេ សីលសំវរំ ។**

*ព្រោះដូច្នោះ កុលបុត្រអ្នកមានសទ្ធា កាលនឹងជម្រះនូវបាតិមោក្ខសំវរសីលឲ្យបរិសុទ្ធ គប្បីស៊ូលះបង់ សូម្បីទាំងជីវិតដោយពិត មិនគប្បីទម្លាយបាតិមោក្ខសំវរសីល ដែលព្រះលោកនាថជាម្ចាស់ទ្រង់បញ្ញត្តហើយនោះឡើយ ។*

**កីកីវ អណ្ឌំ ចមរីវ វាលធឹ បិយំវ បុត្តំ**
**នយនំវ ឯកកំ តថេវ សីលំ អនុរក្ខមានកា**
**សុបេសលា ហោថ សទា សគារវា ។**

*សត្វត្រដេវវិច រក្សានូវស៊ុតវាយ៉ាងណា សត្វចាមរីរក្សានូវកន្ទុយវា យ៉ាងណា មាតារក្សានូវកូនប្រុសតែមួយយ៉ាងណា ជនមានភ្នែកតែម្ខាង រក្សានូវភ្នែក យ៉ាងណាមិញ អ្នកទាំងឡាយចូរជាអ្នកមានសីលជាទីស្រលាញ់ ជាអ្នកប្រកបដោយសេចក្តីគោរពក្នុងសីល ចូរតាមរក្សាសីលឲ្យបានសព្វកាល ក៏យ៉ាងនោះដែរ ។*

**សាសនេ កុលបុត្តានំ    បតិដ្ឋា នត្ថិ យំ វិនា**

**អានិសំសំ បរិច្ឆេទំ    តស្ស សីលស្ស កោ វទេ ។**

*ទីពឹងរបស់កុលបុត្រទាំងឡាយ ក្នុងសាសនានេះ វៀរតែសីលចេញហើយ នឹងមានមកអំពីណា អ្នកណាហ្ន៎ នឹងកំណត់ (ពណ៌នា) នូវអានិសង្សរបស់សីលបាន ។*

**សីលេន សុគតឹ យន្តិ    សីលេន ភោគសម្បទា**

**សីលេន និព្វុតឹ យន្តិ    តស្មា សីលំ វិសោធយេ ។**

*សត្វទាំងឡាយបានទៅកាន់ស្ថានសួគ៌ ក៏ព្រោះសីល បានភោគៈ ក៏ព្រោះសីល បានទៅកាន់ទីរំលត់ទុក្ខគឺព្រះនិព្វាន ក៏ព្រោះសីល ព្រោះហេតុដូច្នោះហើយ សាធុជនទាំងឡាយ គប្បីជម្រះសីលឲ្យបរិសុទ្ធ កុំឲ្យសៅហ្មងឡើយ ។*

**សីលំ យោគិស្ស លង្ការោ    សីលំ យោគិស្ស មណ្ឌនំ**

**សីលេហិ លង្កតោ យោគី    មណ្ឌនេ អគ្គតំ គតោ ។**

*សីលជាគ្រឿងអលង្ការរបស់យោគី (អ្នករក្សាសីល) សីលជាគ្រឿងប្រដាប់របស់យោគី, យោគី ប្រដាប់តាក់តែងដោយសីលទាំងឡាយហើយ តែងបាននូវភាវៈខ្ពង់ខ្ពស់ក្នុងការប្រដាប់(កាយ) ។*

**ន បុប្ផគន្ធោ បដិវាតមេតិ ចន្ទនំ តគរមល្លិកា វា**
**សតញ្ច គន្ធោ បដិវាតមេតិ សព្វា ទិសា សប្បុរិសោ**
**បវាយាតិ ។**

*ក្លិនផ្កាបក់ផ្សាយច្រាសខ្យល់ពុំបានទេ ក្លិនខ្លឹមចន្ទន៍ក្ដី ក្លិនក្រស្នាក្ដី ក្លិនផ្កាម្លិះរួតក្ដី បក់ផ្សាយច្រាសខ្យល់ពុំបានទេ មានតែក្លិននៃពួកសប្បុរស (អ្នកមានសីល) ទើបបក់ផ្សាយច្រាសខ្យល់បាន សប្បុរសអ្នកមានសីលបក់ផ្សាយក្លិនសព្វទិសានុទិស(គឺទាំងទីបណ្ដោយខ្យល់ ទាំងទីច្រាសខ្យល់)។*

**ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី**
**ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។**

*ខ្លឹមចន្ទន៍ក្ដី ក្រស្នាក្ដី ផ្កាឧប្បលក្ដី ផ្កាម្លិះលាក្ដី (សុទ្ធតែមានក្លិនក្រអូប) ប៉ុន្តែ ក្លិនសីលក្រអូបក្រៃលែងជាងគន្ធជាតទាំងនុ៎ះ (ឥតមានគន្ធ-ជាតអ្វីក្រអូបដូចសីលឡើយ) ។*

**អប្បមត្តោ អយំ គន្ធោ យ្វាយំ តគរចន្ទនី**
**យោ ច សីលវតំ គន្ធោ វាតិ ទេវេសុ ឧត្តមោ ។**

គ្លិនក្រស្នា និងក្លិនចន្ទន៍ណា ក្លិននេះ ក្រអូបមានប្រមាណតិចទេ ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយណា ក្លិននោះទើបក្រអូបលើស-លប់ ផ្សាយទៅក្នុងទេវលោកនិងមនុស្សលោកបាន ។

**តេសំ សម្បន្នសីលានំ អប្បមាទវិហារិនំ**

**សម្មទញ្ញា វិមុត្តានំ មារោ មគ្គំ ន វិន្ទតិ ។**

មារាធិរាជ (ទុកជាខំស្វែងរក) ក៏មិនជួបនូវផ្លូវរបស់លោកមាន សីលបរិបូណ៌ អ្នកនៅដោយសេចក្តីមិនប្រមាទ អ្នករួចស្រឡះ(ចាកធមិជា គ្រឿងសៅហ្មង) ព្រោះដឹងច្បាស់តាមហេតុ ។

## លាភសក្ការៈសម្លាប់បុគ្គលពាល

ប្រារព្ធភិក្ខុទេវទត្ត

**ផលំ វេ កទលឹ ហន្តិ ផលំ វេឡុំ ផលំ នឡំ**

**សក្ការោ កាបុរិសំ ហន្តិ គព្ភោ អស្សតរឹ យថា ។**

ផ្លែចេក រមែងសម្លាប់ដើមចេក ផ្លែឫស្សី រមែងសម្លាប់ដើមឫស្សី ផ្លែបបុស រមែងសម្លាប់ដើមបបុស (យ៉ាងណា) លាភសក្ការៈរមែងសម្លាប់ បុរសអាក្រក់ ដូចជាគភ៌រមែងសម្លាប់មេសេះអស្សតរ យ៉ាងដូច្នោះ ។

## ធម៌មិនប្រសើរ៤យ៉ាង

**អលសោ គិហី កាមភោគី ន សាធុ**

**អសញ្ញតោ បព្វជិតោ ន សាធុ**

**រាជា ន សាធុ អនិសម្មការី**

**យោ បណ្ឌិតោ កោធនោ តំ ន សាធុ ។**

- គ្រហស្ថអ្នកបរិភោគកាម ខ្ជិលច្រអូស មិនល្អ,
- អ្នកបួស មិនសង្រួម មិនល្អ,
- ព្រះរាជា អ្នកពិចារណាហើយធ្វើ មិនល្អ,
- បណ្ឌិត ដែលមានសេចក្ដីក្រោធនោះ មិនល្អ ។

(បិ. ៥៩/២០១+៦០/១១២)

## អំពើល្អនិងអាក្រក់

**សុករំ សាធុនា សាធុ សាធុ បាបេន ទុក្ករំ**

**បាបំ បាបេន សុករំ បាបមរិយេហិ ទុក្ករំ ។**

- អំពើល្អ មនុស្សសប្បុរស ធ្វើបានដោយងាយ,
- អំពើល្អ មនុស្សអាក្រក់ ធ្វើបានដោយក្រ,
- អំពើបាប មនុស្សបាប ធ្វើបានដោយងាយ,
- អំពើបាប ព្រះអរិយៈ ធ្វើបានដោយក្រ ។

## ដំណើរផ្លូវ

**គតិ មិគានំ បវនំ អាកាសោ បក្ខីនំ គតិ**

**វិភាវោ គតិ ធម្មានំ និព្វានំ អរហតោ គតិ ។**

- ព្រៃ ជាដំណើររបស់ពួកម្រឹគ,
- អាកាស ជាដំណើររបស់ពួកបក្សី,
- សេចក្ដីវិនាស ជាដំណើររបស់សង្ខតធម៌ទាំងឡាយ,

- *ព្រះនិព្វាន ជាដំណើររបស់ព្រះអរហន្ត ។*

## បុថុជ្ជនថោកទាប

**ឯកោ បុព្វេ ចរិត្វាន មេថុនំ យោ និសេវតិ**
**យានំ ភន្តំ វ តំ លោកេ ហីនមាហុ បុថុជ្ជនំ ។**

*បុគ្គលណា ប្រព្រឹត្តតែម្នាក់ឯង (គឺបួស) ក្នុងកាលមុន ហើយ (ត្រលប់មក)សេពមេថុនធម្មវិញ អ្នកប្រាជ្ញទាំងឡាយហៅបុគ្គលនោះថា* ***បុថុជ្ជនថោកទាបក្នុងលោក*** *ដូចជាយានដែលភ្លូកហើយ។*

**យសោ កិត្តិ ច យា បុព្វេ ហាយតេ វាបិ តស្ស**
**សា ឯតម្បិ ទិស្វា សិក្ខេថ មេថុនំ វិប្បហាតវេ ។**

*យសនិងកេរ្តិ៍ឈ្មោះណា (ធ្លាប់មានហើយ) ក្នុងកាលមុន យសនិងកេរ្តិ៍ឈ្មោះរបស់បុគ្គលនោះ ក៏សាបសូន្យទៅ បព្វជិតឃើញនូវដំណើរនោះហើយ គប្បីសិក្សាដើម្បីលះបង់មេថុនធម្ម ។* (បិ.៦៤/២៧៣+២៧៩)

## មាតាបិតា

**ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ**
**អាហុនេយ្យា ច បុត្តានំ បជាយ អនុកម្បកា ។**

*មាតាបិតាទាំងឡាយ ដែលហៅថា ព្រហ្មក្តី បុព្វាចារ្យក្តី អាហុនេយ្យៈ ក្តី (សុទ្ធតែ) ជាអ្នកអនុគ្រោះដល់ពួកសត្វគឺកូន ។*

**តស្មា ហិ នេ នមស្សេយ្យ សក្ករេយ្យ ច បណ្ឌិតោ**

**អន្នេន អថោ បានេន វត្ថេន សយនេន ច**
**ឧច្ឆាទនេន ន្ហាបនេន បាទានំ ធោវនេន ច ។**

*ព្រោះហេតុនោះឯង អ្នកប្រាជ្ញគួរនមស្ការ គួរធ្វើសក្ការៈដល់មាតាបិតាទាំងនោះដោយ បាយ ទឹក សំពត់ គ្រឿងដេក គ្រឿងអប់ គ្រឿងផ្ងូតទឹក និងទឹកសម្រាប់លាងជើង ។*

**តាយ នំ បារិចរិយាយ មាតាបិតូសុ បណ្ឌិតា**
**ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតិ ។**

*ព្រោះការបានទំនុកបម្រុងមាតាបិតានោះហើយ បានជាអ្នកប្រាជ្ញទាំងឡាយសរសើរនូវបុគ្គលនោះក្នុងលោកនេះឯង បុគ្គលនោះលុះលះលោកនេះទៅហើយ រមែងរីករាយក្នុងឋានសួគ៌ ។* (បិ.៥៣/១៤២)

## អំពីរដូវ

### តាមចន្ទគតិមាន ៣ រដូវក្នុង ១ ឆ្នាំ

១- ***គិម្ហរដូវ***: ១រោច ផល្គុន – ១៥កើត អាសាឍ
២- ***វស្សានរដូវ***: ១រោច អាសាឍ – ១៥កើត កត្តិក
៣- ***ហេមន្តរដូវ***: ១រោច កត្តិក – ១៥កើត ផល្គុន

| | | |
|---|---|---|
| ១- មិគសិរ | ២- បុស្ស | ៣- មាឃ |
| ៤- ផល្គុន | ៥- ចេត្រ | ៦- វិសាខ |
| ៧- ជេស្ឋ | ៨- អាសាឍ | ៩- ស្រាពណ |
| ១០- ភទ្របទ | ១១- អស្សុជ | ១២- កត្តិក ។ |

**តាមសុរិយគតិមាន ៤ រដូវក្នុង ១ ឆ្នាំ**

១- ***សិសិរ***: ពីថ្ងៃទី ២២ ធ្នូ – ២០ មិនា (៨៩ឬ៩០ថ្ងៃ)

២- ***និទាឃ***: ពីថ្ងៃទី ២១ មិនា – ២១ មិថុនា (៩៣ថ្ងៃ)

៣- ***វស្សាន***: ពីថ្ងៃទី ២២ មិថុនា – ២២ កញ្ញា (៩៣ថ្ងៃ)

៤- ***សរទ*** : ពីថ្ងៃទី ២៣ កញ្ញា – ២១ ធ្នូ (៩០ថ្ងៃ) ។

| | | | |
|---|---|---|---|
| មករា | មាន ៣១ ថ្ងៃ | កុម្ភៈ | មាន ២៨ ថ្ងៃ |
| មិនា | មាន ៣១ ថ្ងៃ | មេសា | មាន ៣០ ថ្ងៃ |
| ឧសភា | មាន ៣១ ថ្ងៃ | មិថុនា | មាន ៣០ ថ្ងៃ |
| កក្កដា | មាន ៣១ ថ្ងៃ | សីហា | មាន ៣១ ថ្ងៃ |
| កញ្ញា | មាន ៣០ ថ្ងៃ | តុលា | មាន ៣១ ថ្ងៃ |
| វិច្ឆិកា | មាន ៣០ ថ្ងៃ | ធ្នូ | មាន ៣១ ថ្ងៃ ។ |

**តាមប្រទេសខ្លះនិយមប្រើរដូវ ៦ គឺ :**

១- ***ហេមន្តរដូវ*** ពីថ្ងៃ១រោច ខែកត្តិក ដល់ ថ្ងៃ១៥កើត ខែបុស្ស ត្រូវជា៥៩ថ្ងៃ ។

២- ***សិសិររដូវ*** ពីថ្ងៃ១រោច ខែបុស្ស ដល់ ថ្ងៃ១៥កើត ខែផល្គុន ត្រូវជា៥៩ថ្ងៃ ។

៣- ***វសន្តរដូវ*** ពីថ្ងៃ១រោច ខែផល្គុន ដល់ថ្ងៃ១៥កើត ខែពិសាខ ត្រូវជា៥៩ថ្ងៃ ។

៤- **គិម្ហរដូវ** ពីថ្ងៃ១រោច ខែពិសាខ ដល់ ថ្ងៃ១៥កើត ខែអាសាឍ

*ត្រូវជា៥៩ថ្ងៃ ។*

*(បើឆ្នាំដែលមានអធិកវារៈ មាន៦០ថ្ងៃ, ឆ្នាំដែលមានអធិកមាស៣ ខែ មានថ្ងៃ ៨៩(?) ព្រោះប្រើខែចេញឈ្មោះតាមចន្ទគតិ ដូចបែបប្រើរដូវ ៣ដែរ) ។*

*៥- **វស្សានរដូវ** ពីថ្ងៃ១រោច ខែអាសាឍ ដល់ ថ្ងៃ១៥កើត ខែភទ្របទ ត្រូវជា៥៩ថ្ងៃ ។*

*៦- **សរទរដូវ** ពីថ្ងៃ១រោច ខែភទ្របទ ដល់ ថ្ងៃ១៥កើត ខែកត្តិក ត្រូវជា៥៩ថ្ងៃ ។*

*- រួមទាំង ៦ រដូវមាន ១២ ខែ (ឬចួនកាលមាន១៣ខែ?) មាន៣៥៤ (ឬ ៣៥៥ថ្ងៃ ឬក៏ចួនកាល ៣៨៤ថ្ងៃ?) ត្រូវជា១ឆ្នាំ ។*

........................

# ពុទ្ធប្បវត្តិសង្ខេប

| ព្រឹត្តិការណ៍ | ថ្ងៃ | ខែ | ឆ្នាំ | ព្រះជន្ម |
|---|---|---|---|---|
| បដិសន្ធិ | ព្រហស្បតិ៍ | អាសាឍ | រកា | |
| ប្រសូត | សុក្រ | ពិសាខ | ច | |
| អភិសេក | អាទិត្យ | កត្តិក | ឆ្លូវ | ១៦ |
| បួស | ព្រហស្បតិ៍ | អាសាឍ | ថោះ | ២៩ |
| ត្រាស់ដឹង | ពុធ | ពិសាខ | រកា | ៣៥ |
| កំណត់សង្ខារ | សុក្រ | មាឃ | រោង | |
| និព្វាន | អង្គារ | ពិសាខ | ម្សាញ់ | ៨០ |

| សកម្មភាព | ឆ្នាំ | ខែ | ថ្ងៃ | ពេល |
|---|---|---|---|---|
| ចាប់ | រ | អា | ព្រ | ទៀបភ្លឺ |
| ប្រ | ច | ពិ | សុ | ជិតត្រង់ |
| រាជ្យ | ឆ្លូវ | ក | អា | ថ្ងៃ |
| បួស | ថោះ | អា | ព្រ | អធ្រាត្រ |
| ត្រាស់ | រ | ពិ | ពុធ | ទៀបភ្លឺ |
| កំ | រោង | មាឃ | សុ | ព្រឹក |
| និ | ម្សាញ់ | ពិ | អង្គ | ទៀបភ្លឺ |

* * * * * * * *

## សមាគមអាស៊ាន

***អាស៊ាន*** *មានន័យថា សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ មកពីពាក្យពេញជាភាសាអង់គ្លេសថា* Association of South East Asian Nation. *ហៅកាត់ថា* Asean ។ Asean *មានផ្ទៃដីសរុប ៤.៤៦៥.៣២២* Km2 ។ Asean *បានបង្កើតឡើងនៅ ថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧ នាទីក្រុងបាងកក ប្រទេសថៃ ដែលផ្ដើមឡើងដោយប្រទេសទាំង ៥គឺ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបូរី និង ប្រទេសថៃ ។*

Asean *មានគោលដៅ៣ មានគោលបំណង១៥ មានគោលការណ៍១៤ ហើយក្នុងរដ្ឋធម្មនុញ្ញមាន១៣ចំពូក និង៥៥មាត្រា ។*

## ប្រទេសជាសមាជិកអាស៊ានទាំង១០

| ឈ្មោះប្រទេស | កាលបរិច្ឆេទ | ផ្ទៃដី |
|---|---|---|
| ប្រទេសឥណ្ឌូនេស៊ី | ៨ - ៨ - ១៩៦៧ | ១.៩០០.០០០ Km2 |
| ប្រទេសម៉ាឡេស៊ី | ៨ - ៨ - ១៩៦៧ | ៣២៩.៧៥៨ Km2 |
| ប្រទេសហ្វីលីពីន | ៨ - ៨ - ១៩៦៧ | ៣០០.០០០ Km2 |
| ប្រទេសសិង្ហបូរី | ៨ - ៨ - ១៩៦៧ | ៦.៤៦១Km2 |
| ប្រទេសថៃ | ៨ - ៨ - ១៩៦៧ | ៥១៣.០០០ Km2 |
| ប្រទេសប្រ៊ុយនេ | ៨ - ១ - ១៩៨៤ | ៥.៧៦៩ Km2 |
| ប្រទេសវៀតណាម | ២៨ - ៧ - ១៩៩៥ | ៣៣១.៦៨៩ Km2 |
| ប្រទេសឡាវ | ២៤ - ៧ - ១៩៩៧ | ២៣៦.៨០០ Km2 |
| ប្រទេសភូមា | ២៤ - ៧ - ១៩៩៧ | ៦៧៨.០៣៣ Km2 |
| ប្រទេសកម្ពុជា | ៣០ - ៤ - ១៩៩៩ | ១៨១.០៣៥ Km2 |

### និមិត្តសញ្ញានិងទង់អាស៊ាន

និមិត្តសញ្ញាអាស៊ាន និង ទង់អាស៊ានតំណាងឲ្យសមាគមអាស៊ានមួយ ដែលមានស្ថិរភាព សន្តិភាព សាមគ្គីភាព ភាពអង់អាចនិងប្រកបដោយថាមពល ។ ពណ៌និងនិមិត្តសញ្ញានៃទង់អាស៊ានមានពណ៌ខៀវ ក្រហម ស លឿង ដែលពណ៌ទាំងអស់នេះតំណាងឲ្យពណ៌សំខាន់នៃទង់ជាតិរបស់ប្រទេសសមាជិកទាំងអស់ ។

- **ពណ៌ខៀវ** តំណាងឲ្យសន្តិភាព និងស្ថេរភាព ។

- ***ពណ៌ក្រហម*** តំណាងឲ្យសេចក្ដីក្លាហាន និង ភាពស្វាហាប់ដ៏ប្រកបដោយថាមពល ។

- ***ពណ៌ស*** តំណាងឲ្យភាពបរិសុទ្ធិ ស្អាតស្អំ ។

- ***ពណ៌លឿង*** តំណាងឲ្យវិបុលភាព ភាពសម្បូរណ៍សប្បាយ ។

- ***ដើមស្រូវទាំង ១០*** តំណាងឲ្យសុបិនរបស់បិតាបង្កើតអាស៊ានដែលមានបំណងប្រមូលផ្ដុំ ប្រទេសទាំង១០នៅអាស៊ីអាគ្នេយ៍ឲ្យក្លាយជាសហគមមួយប្រកបដោយមិត្តភាព និងសាមគ្គីភាព។

- ***រង្វង់ព័ទ្ធជុំវិញ*** តំណាងឲ្យភាពឯកភាពគ្នារបស់អាស៊ាន ។

.................................

## អវសានគាថា

និរយំ បាបកម្មិនោ ពួកអ្នកមានអំពើអាក្រក់ ទៅកាន់នរក
សគ្គំ សុគតិនោ យន្តិ ពួកអ្នកមានគតិល្អ ទៅកាន់ឋានសួគ៌
បរិនិព្វន្តិ អនាសវា ពួកអ្នកមិនមានអាសវៈ បរិនិព្វាន ។

(បិ.៥២/៤៨)

(ថ្ងៃទី៨ -១០- ២០១៣→៦ -១០- ២០១៤)

# ច្បាប់រាជនេតិ

ប្រើថ្លឹងឱ្យស្មើ ទោះបីនឹងប្រើ ប្រើអ្នកចេះក្តី

កុំយកពាក្យស្លោក ផ្ទឹមនឹងគម្ពីរ កុំយកពាក្យជី

ផ្ទឹមនឹងពាក្យពាល ។

សម្តេច ធម្មរាជា រាជសម្ភារ